CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ សម្រាប់ខែមិថុនា ឆ្នាំ២០១៦ លក់តម្លៃ ១០០០រៀល

លេខ ៩៤



# ព្រះសហគមន៍ប្រារព្ធបុណ្យគំរប់ខួប ១០០ថ្ងៃ របស់លោកអភិបាលអេមីល នៅតាំងគោក

## សេចក្តីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូន ជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ឆ័ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្តល់ព័ត៌មានបន្ថែម អំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទ ឬសៀវភៅដែលគាត់សរសេរវត្ថុអនុស្សាវរីយរបស់គាត់ ខ្លះ។ល។ សូមផ្តល់ឈ្មោះអ្នកដែលអាចផ្តល់សក្ខីភាពបានជូនមកខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

Tel : 077 800 211 / 096 34 22 144

ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

Email: martyrscambodia@gmail.com

# រូបភាពប្រចាំខែ



ពលរដ្ឋកម្ពុជាយល់ពីផលប៉ះពាល់នៃសំរាមផ្លាស្ទិច ប៉ុន្តែភាគច្រើននៅតែជៀសមិនផុតពីការប្រើប្រាស់ផលិតផលដែលផលិតពីផ្លាស្ទិចដែលមាន ដូចជា កែវ ប្រអប់ស្នោ ថង់ ដប បំពង់បឺត ... ខណៈដែលអ្នកផ្តលសេវាកម្ម អាហារ ភេសជ្ជៈ និងសេវាកម្មមួយចំនួនតាំងពី ចល័តតាមចិញ្ចើមផ្លូវ រហូតដល់ហាងធំៗទំនើបមានឃីហោត្រឹមត្រូវ គឺបានបោះបង់ចោលនូវកែវ ពែង និងសម្ភារមួយចំនួនដើម្បីភាពងាយស្រួលនៃអាជីវកម្មរបស់ពួកគេ។



ការកាត់បន្ថយសម្រាមផ្លាស្ទិច គឺចេញពីអ្នកប្រើប្រាស់ម្នាក់ៗ ប៉ុន្តែជាទូទៅនៅក្នុងជីវភាពរស់នៅសព្វថ្ងៃផ្លាស្ទិចនៅតែសំខាន់។ បើម្នាក់ៗអាចកាត់បន្ថយពីការប្រើប្រាស់សម្ភារដែលប្រើប្រាស់ផលិតពីផ្លាស្ទិចនោះ យុទ្ធសាស្ត្រនិងការលើកទឹកចិត្តរបស់អាជ្ញាធរឆ្ពោះទៅរកយុទ្ធនាការកម្ពុជាគ្មានផ្លាស្ទិចប្រហែលជាវិជ្ជមាន។ "ការកាត់បន្ថយផ្លាស្ទិចមិនមែនជាកាតព្វកិច្ចអាជ្ញាធរទេ តែជារបស់យើងទាំងអស់គ្នា"។



បើមួយថ្ងៃម្នាក់ប្រើផ្លាស្ទិកដូចជា ថង់ផ្លាស្ទិច កំប៉ុងទឹក កំពុងភេសជ្ជៈ ប្រអប់ស្នោដាក់បាយមួយប្រអប់ ដបទឹកសុទ្ធមួយដប បរិស្ថាននៅក្នុងទីក្រុងភ្នំពេញ នឹងមានស្ថានភាពលើសពីគំនរសំរាមតាមបណ្តោយផ្លូវនៅក្នុងភូមិមួយកន្លែងនៅក្នុងសង្កាត់ព្រែកប្រាខណ្ឌមានជ័យដែលបានឃើញនេះទៅទៀតរាប់សិបដង !



នេះគឺជាទិដ្ឋភាពជាក់ស្តែងនៅប្រឡាយទឹកស្អុយមួយកន្លែងនៅម្តុំបឹងត្របែកដែលជាច្រកចេញនៃទឹកស្អុយចេញពីកណ្តាលរាជធានីភ្នំពេញ។ ច្រកចេញនៃទឹកស្អុយនេះ គឺកំពុងតែប្រឡាយ នឹងសំរាមផ្លាស្ទិច ដែលមានដូចជា សំបកដប ស្បោង កំប៉ុង ប្រអប់ស្នោ... ដែលកើតចេញពីការចោលសំរាមដែលខ្វះការទទួលខុសត្រូវរបស់មនុស្សម្នាក់ៗ។


Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org



ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# កាលបរិច្ឆេទបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទីបួនបានប្រកាសហើយ !

ថ្មីៗនេះរាជរដ្ឋាភិបាលបានចេញនូវសេចក្តីប្រកាសស្តីពីកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទីបួន នឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ គិតចាប់ពីពេលនេះទៅ គឺមានរយៈពេលមួយឆ្នាំ។

កំដៅនយោបាយនៅកម្ពុជាបច្ចុប្បន្ន ម្តងឡើង ម្តងចុះមិនទៀងទាត់ អ្នកនយោបាយម្តងត្រូវរ៉ូវគ្នាល្អកល្អិន ម្តងស្មើរស៊ីសាច់ហុតឈាមគ្នា។ ប៉ុន្តែយើងជាពលរដ្ឋសូមកុំភ្លេចបំពេញកាតព្វកិច្ចរបស់ខ្លួនគឺត្រូវបញ្ចេញឆន្ទៈរបស់ខ្លួនជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន ជាពិសេសគឺថ្នាក់ដឹកនាំនៅមូលដ្ឋានដែលយើងរស់នៅ។

ជុំវិញសភាពការណ៍នយោបាយទាំងនេះ ម្នាក់ៗសូមកុំឲ្យចូលជ្រៅឲ្យផុងទៅក្នុងនយោបាយរបស់អ្នកនយោបាយ ប៉ុន្តែត្រូវ ចាប់ផ្តើមធ្វើការវាយតម្លៃ ថាតើក្នុងមូលដ្ឋានរបស់ខ្លួន គណបក្សដែលយើងបោះជូនកន្លងមកឲ្យដឹកនាំមូលដ្ឋានកន្លងទៅអាចឆ្លើយតបតាមសេចក្តីត្រូវការរបស់យើងឬទេ? តើពួកគេដឹកនាំមូលដ្ឋានឲ្យត្រូវ និងគោលនយោបាយភូមិឃុំមានសុវត្ថិភាពដែលលើកឡើងឬអត់ តើពួកគេពិតជាបានទប់ស្កាត់បានល្អ លែងធ្វើឲ្យពលរដ្ឋមូលដ្ឋានព្រួយបារម្មណ៍ហើយឬនៅ? ឬក៏ពេលចេញទៅណាមកណាមកវិញគឺមានតែសំបកផ្ទះ? តើរាល់សេចក្តីត្រូវការរបស់ពលរដ្ឋ មេឃុំ ចៅសង្កាត់ អាជ្ញាធរមានសមត្ថកិច្ច ដោះស្រាយជូនពលរដ្ឋត្រឹមត្រូវឬទេ? ឬក៏មានលុយមានខ្នង ឈ្នះរហូត ឬទុកចោលមិនចាត់ការ? តើផ្លូវថ្នល់ ប្រឡាយទឹកល្អ ក្នុងតំបន់របស់ខ្លួនយ៉ាងណាដែរ?...

ពលរដ្ឋម្នាក់ៗគួរសម្លឹងមើលគុណសម្បត្តិបុគ្គលណាម្នាក់ដែលមានសមត្ថភាពនៅក្នុងគណបក្ស ដែលអាចដឹកនាំបម្រើពលរដ្ឋមូលដ្ឋានបានពិតប្រាកដគឺមិនចាំបាច់ ប្រកាន់និន្នាការគណបក្សនយោបាយឡើយ។

ពេលវេលាមួយឆ្នាំមិនយូរទេ អ្នកមានកាតព្វកិច្ចបោះឆ្នោតទាំងអស់ត្រូវត្រៀមរាល់ឯកសារដើម្បីទៅចុះឈ្មោះបោះឆ្នោតពោល គឺមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាដើម។ ត្រូវទៅចុះឈ្មោះបោះឆ្នោតឲ្យបានគ្រប់ៗគ្នា។ ជាងនេះទៅទៀតត្រូវតែតាមដានព័ត៌មាននានាទាក់ទង និងការចុះឈ្មោះ បោះឆ្នោតសេចក្តីប្រកាសទាក់ទង និងការបោះឆ្នោតព័ត៌មានពីមណ្ឌល និងការិយាល័យបោះឆ្នោត។ ពេលគួរបោះស្វែងយល់ពីគោលនយោបាយរបស់គណបក្សនីមួយៗដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត តើបុគ្គលណាមកពីគណបក្សណាជាដើម។ ចូរប្រុងប្រយ័ត្នរាល់ការអូសទាញនានា ការគម្រាមកំហែង ឬការសន្យាមិនបានការនោះឡើយ។

កន្លងមកមានទស្សនៈខុសឆ្គងមួយចំនួនបានលេចចេញឡើងគឺ បោះឲ្យនរណា ក៏ដូចនរណាដែរដូច្នេះមិនចាំបាច់បោះនោះទេ។ ត្រង់នេះ គឺពិតជាខុសឆ្គងទាំងស្រុង។ ការជ្រើសរើសផ្ទាល់ខ្លួនប្រសើរជាង អ្នកដទៃជ្រើសរើសជំនួសយើង។ យើងពេញចិត្តបុគ្គលណា ត្រូវតែជ្រើសរើលបុគ្គលនោះ ព្រោះថា បើគាត់ធ្វើមិនបានល្អ គឺយើងជ្រើសរើសអ្នកផ្សេង យើងជាពលរដ្ឋជាអ្នកតាមដានឃ្លាំមើល រាល់សកម្មភាពរបស់ចៅសង្កាត់ ឬមេឃុំ។ បើយើងមិនបានបោះឆ្នោត គឺបាត់បង់ឱកាសផ្ទាល់ខ្លួនឯងក្នុងការជ្រើសរើសមនុស្សដែលខ្លួនពេញចិត្ត ហើយក៏មិនបានបំពេញកាតព្វកិច្ចជាលរដ្ឋក្នុងសង្គមកម្ពុជាផងដែរ។

អ្នកនាំសារក៏សូមសរសើរដល់ពលរដ្ឋដែលយកចិត្តទុកដាក់ខ្នះខ្នែងចំពោះការចុះឈ្មោះ ស្វែងរកព័ត៌មាននានាទាក់ទងនឹងការបោះឆ្នោត សូមលើកទឹកចិត្តឲ្យបន្តសកម្មភាពនេះទៀត។ អ្នកនាំសារសូមរំលឹកមួយដែរ កុំចាញ់បោកអ្នកនយោបាយ។ យើងបោះឆ្នោតជ្រើសរើសគេ ដើម្បីផ្តល់សេវាសាធារណដល់យើងជាពលរដ្ឋ។

សរុបទៅពលរដ្ឋគ្រប់រូបសូមត្រៀមខ្លួនឲ្យបានរួចរាល់ នូវគ្រប់ឯកសារនានាដែលពាក់ព័ន្ធ ហើយទៅចុះឈ្មោះបោះឆ្នោត ដើម្បីទទួលបានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់អណាត្តិទីបួន ឆ្នាំ២០១៧។



*លោក លី សុវណ្ណា*
*ចាងហ្វាងកាសែតអ្នកនាំសារ*

# ព្រះសហាគមន៍ប្រារព្ធបុណ្យខួបគំរប់១០០ថ្ងៃរបស់លោកអភិបាលអេមីល នៅតាំងគោក



ព្រះសគមន៍កាតូលិកនៅកម្ពុជាបានប្រារព្ធបុណ្យខួប១០០ថ្ងៃ សម្រាប់សពលោកអេមីល ដេតម្ប អតីតអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នៅជីនៃក្តីសង្ឃឹម ក្នុងភូមិតាំងគោក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ស្របពេលដែរព្រះហសគមន៍ប្រារព្ធបុណ្យរំឭកដល់អស់គ្រីស្តបរិស័ទកម្ពុជាបានស្លាប់ និងត្រូវគេសម្លាប់ក្នុងសម័យខ្មែរក្រហម។

ពិធីប្រារព្ធឡើងក្រោមអធិបតីភាពលោកអភិបាលភូមិភាគភ្នំពេញ អូលីវីយេ ជ្មឹតអីស្លែរ រួមជាមួយបូជាចារ្យទាំងអស់ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា និងគ្រីស្តបរិស័ទជាងមួយពាន់នាក់។

ពិធីបានចាប់ផ្តើមដោយការអានពីប្រវត្តិរបស់លោកអភិបាលអេមីល ដែលបានទទួលមរណភាពកាលពីចុងខែមករាកន្លងទៅ និងប្រវត្តិទំនាក់ទំនងរបស់លោកជាមួយមរណសាក្សី ក្នុងប្រទេសកម្ពុជា។ លោកអេមីលបានមកប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៦៤ រហូតដល់ពេលដែលខ្មែរក្រហម បណ្តេញចេញពីកម្ពុជា ១៩៧៥។ លោកបានវិលត្រលប់មកប្រទេសកម្ពុជាវិញ នៅដើមទស្សវត្ស ១៩៩០។ មុខងារជាបូជាចារ្យ ជាមន្ត្រីអង្គការក្រៅរដ្ឋាភិបាល ក្នុងមុខងារជាអភិបាលលោកបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការបម្រើព្រះសហាគមន៍ បម្រើបងប្អូន ប្រមែប្រមូលគ្រីស្តបរិស័ទ លើកទឹកចិត្ត និងណែនាំគេឲ្យតាមមាគាររបស់ព្រះជាម្ចាស់ប្រកបដោយព្រហ្មវិហារធម៌ខ្ពស់។ មានស្នាដៃ និងសមិទ្ធផលជាច្រើនដែលលោកបានបន្សល់ទុកសម្រាប់អ្នកបន្តវេនពីលោក គឺលោកអូលីវីយេ។

នៅក្នុងធម្មទេសនាលោកអភិបាល អូលីវីយេ បានអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរមណសាក្សី និងលោកអភិបាល អេមីល ដែលជាគំរូសម្រាប់គ្រីស្តបរិស័ទក្នុងការថែរក្សាជំនឿ ដោយទុកចិត្តលើព្រះជាម្ចាស់គ្រប់កាលៈទេសៈ និងរស់នៅស្របតាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។

លើសពីនេះទៅទៀត តាមរយៈព្រះយេស៊ូជាសេចក្តីពិត ដែលជាចិត្តស្រឡាញ់ បម្រើ អធិដ្ឋាន និងលើកលែងទោស លោកអភិបាលបានជំរុញឲ្យយើងអនុវត្តន៍សេចក្តីពិត ឲ្យដូចជាព្រះយេស៊ូនៅក្នុងសង្គម និងដោយមានចិត្តស្មោះត្រង់ មិនពុករលួយ ហើយក៏មិនមានល្បិចផងដែរ។

លោកអេមីល ដេមត្ប ប្រសូតនៅថ្ងៃទី១៥ សីហា ១៩៣៥ ក្នុងគ្រួសារកសិករមួយនៅប្រទេសបារាំង មានបងប្អូន ១៧នាក់។ លោកទទួលអគ្គសញ្ញាតែងតាំង បូជាចារ្យនៅថ្ងៃទី២១ ធ្នូ ១៩៦១ លោកទទួលអគ្គសញ្ញាតែងតាំងជាអភិបាលក្នុងឆ្នាំ១៩៩៧ ទទួលមុខងារជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក្នុងឆ្នាំ ២០០១ រហូតដល់ឆ្នាំ២០១០។ លោកទទួលមរណភាព ថ្ងៃទី២៨ មករា ២០១៦។ សពលោកត្រូវបានបញ្ចុះនៅប្រទេសកម្ពុជាទឹកដីដែលលោកស្រឡាញ់ជាទីបំផុត។

*ដោយ ដាលីស*

# គ្រោះរាំងស្ងួតឆ្នាំនេះអាក្រក់បំផុតនៅក្នុងរយៈពេល៣៧ឆ្នាំ

បើទោះបីជាលទ្ធផលនៃការព្យាករណ៍ ឬប៉ាន់ប្រមាណអំពីតម្លៃនៃផលប៉ះពាល់ដោយគ្រោះរាំងស្ងួតឆ្នាំនេះ មិនត្រូវបានគេប្រកាស ប៉ុន្តែទំហំនៃការខូចខាត និងផលប៉ះពាល់ដោយសារតែគ្រោះធម្មជាតិមួយនេះ គឺប្រហែលមិនធម្មតាទេ ខណៈដែលប្រជាពលរដ្ឋមួយចំនួន នៅក្នុងចំណោមប្រជាជនរងគ្រោះ ២,៥ លាននាក់ មានមួយចំនួនបានជម្លៀសខ្លួនមកកាន់ទីក្រុងដើម្បីគេចចេញពីបញ្ហានេះ។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២៨ មេសា ២០១៦ នៅក្នុងពិធីចែកសញ្ញាបត្រ ដល់និស្សិតនៃសាកលវិទ្យាធនធានមនុស្សចំនួន ១.៥៨៩នាក់ថា គ្រោះរាំងស្ងួតនេះអាក្រក់បំផុតដែលមិនធ្លាប់ជួបនៅកម្ពុជាតាំងឆ្នាំ១៩៧៩មក ។

សម្តេចតេជោ ហ៊ុន សែន អំពាវនាវឲ្យពង្រីកនូវទំហំយុទ្ធនាការចែកចាយទឹកជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស ខណៈពេលដែលវិសាលភាពនៃគ្រោះរាំងស្ងួត និងការឡើងកំដៅនៅតែបន្តកើនឡើង និងគ្របដណ្តប់លើតំបន់កាន់តែច្រើននៅក្នុងប្រទេសកម្ពុជា។

លោក កែវ វី អ្នកនាំពាក្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានប្រាប់អ្នកសារព័ត៌មានថា ត្រឹមចុងខែមេសា មានខេត្តចំនួន១៨ កំពុងប្រឈមនឹងបញ្ហាខ្វះខាតទឹកប្រើប្រាស់ ប៉ុន្តែមិនមែនទូទាំងខេត្តទេ គឺនៅមានខេត្តស្រុកខ្លះនៅមានទឹកសេសសល់ប្រើប្រាស់។

លោកបន្តថា ប៉ុន្តែបើស្ថានភាពនេះនៅបន្តត្រឹមតែ១០ ថ្ងៃទៀតនោះតំបន់មួយចំនួន អាចនឹងជួបប្រទះបញ្ហាខ្វះទឹកធ្ងន់ធ្ងរ ហើយច្រើនកន្លែងថែមទៀត។

ជុំវិញបញ្ហាគ្រោះរាំងស្ងួតនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើការពន្យល់បញ្ហាមួយចំនួនដែលត្រូវបានលើក ឡើងទៅកាន់សម្តេចតាមរយៈហ្វេសប៊ុក ដោយស្នើឲ្យមានការធ្វើភ្លៀងសិប្បនិមិត្ត តាមរយៈការបាចម្សៅ នៅលើអាកាសធ្វើឲ្យមានភ្លៀង។ សម្តេចតេជោ បានបន្តថា បញ្ហានេះប្រសិនធ្វើបាននោះ ប្រទេសថៃ និងវៀតណាមមិនពិបាកទេ ព្រោះគេមានលទ្ធភាពជាងយើង ហើយសម្តេចក៏អាចសុំឲ្យថៃជួយបានដែរ តែមិនអាចទៅរួចដោយសារថា នៅលើមេឃវាអត់មានពពក ដូចនេះវាអត់អាចក្លាយជាភ្លៀងបានទេ ហើយបើអាចនោះប្រទេសថៃមិនព្រងើយកន្តើយទេ។

សម្តេចបានបន្តថា ជាមួយនេះក៏មានការស្នើឲ្យមានការជីកស្រះត្រពាំង និងអណ្តូង ជៀសជាងមធ្យោបាយចែកចាយទឹកដោយសម្តេចបានធ្វើការពន្យល់ថា៖ រាជរដ្ឋាភិបាលបានធ្វើការងារនេះរួចហើយ ចំនួនអណ្តូងទឹកនិងស្រះទឹកមានការកើនឡើង១០០ដង។

ពាក់ព័ន្ធ នឹងស្ថានភាពធ្ងន់ធ្ងរដែលបណ្តាលមកពីគ្រោះរាំងស្ងួតនេះសម្តេចតេជោបានឲ្យដឹងថា"នៅក្នុងខេត្តស្វាយរៀងតែមួយអណ្តូងទឹកបានរីកស្ងួតកាន់តែច្រើនដែល កាលពីថ្ងៃទី២៦ ខែមេសា មានអណ្តូងទឹកត្រឹមតែ៣៦០ អណ្តូង ប៉ុណ្ណោះដែលត្រូវរីងស្ងួត តែគិតមកដល់ថ្ងៃទី២៧ ខែមេសា អណ្តូងទឹករហូតដល់ជាង ៦០០ បានរីងស្ងួតដែលនេះជាបញ្ហាដែលគួរឲ្យព្រួយបារម្ភបំផុត"។

ជុំវិញបញ្ហាគ្រោះរាំងស្ងួតនេះប្រជាពលរដ្ឋមួយចំនួនកំពុងតែជួបនឹងបញ្ហានេះបានជម្លៀសខ្លួនពួកគេពីតំបន់រាំងស្ងួតមកកន្លែងដែលមានទឹកបណ្តើរៗហើយ ជាពិសេសគឺទីក្រុងភ្នំពេញ។

លោក ជីន សារ៉េត ជាមន្ត្រីអង្គការក្រៅរដ្ឋាភិបាលមួយរូប ដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងខេត្តព្រៃវែង បានអះអាងថា នៅពេលនេះគាត់បាននាំប្រពន្ធនឹងកូនមកនៅផ្ទះជួលជាមួយលោកហើយ ដោយសារតែនៅផ្ទះខ្វះទឹក និងរាំងស្ងួត។

លោកបានឲ្យដឹងថា កន្លងមកនៅចុងសប្តាហ៍លោកតែងតែធ្វើដំណើរដោយម៉ូតូទៅផ្ទះ ហើយដល់ល្ងាចថ្ងៃអាទិត្យ ទើបមកវិញ ប៉ុន្តែឥឡូវនេះ លោកយកប្រពន្ធនិងកូនអាយុ ៣ឆ្នាំមកនៅជាមួយដោយសារនៅផ្ទះលោកកំពុងតែខ្វះទឹកនិងក្តៅ។

លោកបានបន្តថា "នៅមិនបានទេ វាក្តៅ ហើយអណ្តូងមុខផ្ទះរីង"។

លោកបានបន្តថា អ្នកភូមិនៅពេលនេះ រស់តែមួយនឹងទឹកទិញ ហើយមួយធុង សាំង រាប់ពាន់រៀល ហើយទឹកអត់ស្អាតទៀត ដូច្នេះហើយបានជាលោកបានយកប្រពន្ធមកនៅជាមួយនៅផ្ទះជួលមួយរយៈចាំពេលមានទឹកមានភ្លៀងត្រជាក់ចាំទៅវិញ។

លោកបន្តថា "ខ្ញុំមានរបរនៅទីនោះ ប៉ុន្តែបើក្តៅចឹងគឺបិទមួយរយៈសិនទៅ"។

លោក ហៃ ពិទូ ជាអ្នករត់ម៉ូតូឌុបមួយរូបក៏បានអះអាងថា លោកបាននាំគ្រួសារមកនៅជាមួយ មួយរយៈដែរដោយសារគិតទៅនៅភ្នំពេញពេលនេះ ស្រួលមានទឹក មានភ្លើងតាមបន្ទប់។

លោកបានបញ្ជាក់ថា "នៅខេត្តធ្វើអ្វីបើទិញទឹកគេមួយធុង ១០.០០០រៀលឯណោះ ហើយទឹកឡើងល្អក់"។

លោកបានបញ្ជាក់ថា "នៅស្រែឥឡូវក៏អត់មានអ្វីស៊ីដែរ បើរាំងដីបែកក្រហែងបែបនេះ មកភ្នំពេញ ស៊ីរ៉ះស៊ីថាំ ជុំគ្នាវិញប្រសើរជាង"។

លោកបានបន្តថា បើមានទឹកមានភ្លៀង ទៅប្រពន្ធគេធ្វើនេះធ្វើនោះលក់តាមផ្សារ ដាំនេះដាំនោះ គឺគ្រាន់ផ្សំជីវភាពគ្នា តែនេះធ្វើស្ទីចេញ បើដើរចេញពីក្រោមផ្ទះមិនបានផង ។

នៅដើមខែឧសភា នេះតំបន់មួយចំនួនបានចាប់ផ្តើមមានភ្លៀងឡើងវិញ ប៉ុន្តែបរិមាណទឹកភ្លៀងដែល ធ្លាក់មកគឺតិចមែនទែននៅមិនទាន់អាច នឹងដោះស្រាយបញ្ហានេះបាននៅឡើយទេ ខណៈដែលភ្លៀងនោះទៀតសោតបានបង្អុរមកជាមួយនឹងខ្យល់កន្ត្រាក់ ដែលបណ្តាលឲ្យប្រជាពលរដ្ឋត្រូវរងគ្រោះ រលំបាក់ផ្ទះមួយចំនួនថែមទៀតផងដែរ ។

បន្ទាប់ពីរងគ្រោះនឹងរលកកំដៅ អាស៊ីនឹងប្រឈមព្យុះលេកត្រជាក់ខ្លាំង ឡានីណាវិញម្តង នេះបើតាមការព្យាករណ៍របស់អ្នកវិទ្យាសាស្ត្រ។

គ្រោះរាំងស្ងួត និងអាកាសធាតុក្តៅហែង ដែលបណ្តាលមកពីបាតុភូតរលកកម្តៅអែលនីណូ បានបង្កឱ្យខ្វះស្បៀងនិងទឹក ព្រមទាំងបានបំផ្លាញដំណាំទូទាំងតំបន់អាស៊ី។ ឥឡូវនេះក្រុមអ្នកជំនាញបានមកព្រមានអំពីលទ្ធភាពទឹកជំនន់បង្កឡើងដោយ បាតុភូតជាគូនឹងអែលនីណូ គឺរលកត្រជាក់ឡានីណា វិញម្តង។

ឡានីណា គឺជាបាតុភូតរលកអាកាសធាតុត្រជាក់ទ្វេដងបានមកពីមហាសមុទ្រប៉ាស៊ីហ្វិច ដែលមានសីតុណ្ហភាពត្រជាក់ជាមធ្យមពី ៣ ទៅ៥ អង្សា។

បាតុភូតកម្តៅអែលនីណូដែលបានចាប់ផ្តើមកាលពីឆ្នាំមុន គឺជាបាតុភូតរលកកម្តៅដ៏ក្តៅបំផុតមិនធ្លាប់មាន ដោយបណ្តាលឲ្យទន្លេមេគង្គស្រកចុះទាបបំផុតក្នុងរយៈពេលជាច្រើនទសវត្សរ៍មកនេះ និងបង្កឲ្យមានចលាចលទាក់ទងស្បៀងអាហារនៅក្នុងប្រទេសហ្វីលីពីន និងបានសាយភាយរលកកម្តៅរយៈពេលរាប់ខែនៅទូទាំងតំបន់ ជាមួយនឹងអាកាសធាតុជាមធ្យម ៤០ អង្សា៕



# យុវជន៖ ការជេរប្រមាថតាមហ្វេសប៊ុកមិនមែនជាចំណោទបញ្ហារួមរបស់យុវជន






ការជេរប្រមាថ បង្ហោះកាត់តរូបអសីលធម៌ ការចែករំលែកនូវសារិរៈគន់នយោបាយ...មិនមែនជាចំណោទបញ្ហារបស់យុវជនទៀតឡើយ តែជាចំណោទបញ្ហារបស់អ្នកនយោបាយឬក្រុមយុវជនដែលបម្រើនយោបាយតែប៉ុន្មានក្រុមទេ ឬប៉ុន្មាននាក់ទេ។

ក្រុមយុវនិស្សិតមួយក្រុមកំពុងតែប្រជុំគ្នាស្វ័យសិក្សានៅហាងកាហ្វេតាមស្ទឹលលោកខាងលិចមួយក្រុមបាននិយាយម្នាក់មួយម៉ាត់ម្នាក់មួយសំណួរកាលពីពេលថ្មីៗនេះថា ទង្វើរដែលបានរៀបរាប់ ខាងលើនេះ មិនមែនជាទង្វើរ ឬជាឆន្ទៈរបស់ក្រុមយុវសិស្សសាមញ្ញជនដូចជាពួកគេឡើយ។ ជីវិតជាក្រុមយុវជនជានិស្សិតពួកគេបានធ្វីគឺមានការចែករំលែក មានការកាត់តមានការបង្ហោះរូបភាពនេះរូបភាពនោះ ប៉ុន្តែភាគច្រើន ជាការចែករំលែកដើម្បីកំសាន្ត អប់រំ ជូនព័ត៌មាន និងនិយាយចំអន់គ្នាលេងសើចសប្បាយនៅក្នុងន័យមិត្តភាពតែប៉ុណ្ណោះ។

លីន សុបញ្ញាបុត្រ ជាយុវនិស្សិតឆ្នាំទី៣ ផ្នែកស្ថាបត្យកម្ម បានឲ្យដឹងថា នៅក្នុងចំណោមពួកប្អូននៅក្នុងសម័យនេះ គឺពិតជាមិនអាចរកបានទេ អ្នកដែលមិនស្គាល់បណ្តាញទំនាក់ទំនងសង្គម ជាពិសេស គឺហ្វេសប៊ុក។

បុត្រ បានអះអាងថា "សម័យនេះទៅហើយមនុស្សតិចណាស់ដែលមិនស្គាល់ហ្វេសប៊ុក។ កុំថាឡើយតែក្មេងជាយុវវ័យដូចពួកខ្ញុំសូម្បីតែ ឪពុកម្តាយខ្ញុំ ចាស់ៗ មានដល់នាយករដ្ឋមន្ត្រីផង ក៏នៅលេងហ្វេសប៊ុក"។

បុត្រ និងមិត្តភ័ក្តរបស់ប្អូន គឺពិតជាអះអាងថា ហ្វេសប៊ុក គឺជាវេទិកាសេរី ដែលនរណាចង់ធ្វើអ្វីក៏បានទៅតាមកម្មវិធីដែលគេបានរៀបចំនៅលើនោះ ប៉ុន្តែជាទូទៅសម្រាប់យុវនិស្សិតសាមញ្ញ ដូចជាក្រុមរបស់ពួកគេគឺក្រុមលេងហ្វេសប៊ុកនេះ ឲ្យខុសពីសីលធម៌ ខុសពីប្រពៃណី ខុសពីច្បាប់របស់សង្គម គឺគ្មាន។

បុត្រ បានរៀបរាប់ថា សព្វថ្ងៃនេះអ្វីដែលរូបគេបានលេងនៅក្នុងហ្វេសប៊ុកគឺមានតែចែករំលែករូបភាព កាត់តរូបភាពបែបកំសាន្ត តាមដានព័ត៌មានដែលគេ ស៊ែ (Shares)មកឲ្យ មើលនៅក្នុងផេក (Page) ជជែកគ្នាកំសាន្តលេង ផ្ញើសារ (Message ) ដោយឡែកខ្លឹមសារសំខាន់វិញនោះគឺភាគច្រើន បង្អួត មិត្តភ័ក្ត បញ្ឈឺគ្នាគ្រាន់បានសប្បាយ ហើយជួនកាលពីបបួលគ្នាធ្វើនេះធ្វើនោះមានផឹកកាហ្វេបង្កើតក្លឹបជជែកលេងជាដើម ប៉ុណ្ណោះ ដោយឡែករឿងដែលពាក់ព័ន្ធ និងនយោបាយ គឺមិនដែលបានយកចិត្តទុកដាក់ឲ្យស៊ីជម្រៅឡើយ ។

បុត្របានបញ្ជាក់ថា "តាំងពីខ្ញុំចេះលេងហ្វេសប៊ុកមក សារដែលច្រើនជាងគេនោះ គឺបង្ហោះទេសភាព និងរូបថតឌី(បង្អួត) មិត្តភ័ក្តលេង"។

កញ្ញា ទេស កល្យាណី ជាយុវនារីលេងហ្វេសប៊ុកមួយរូប បានឲ្យដឹងថា កញ្ញា លេងហ្វេសប៊ុកមក បីឆ្នាំហើយ តែមិនដែលចេះចែករំលែក (Share) រូបភាពអ្វីក្រៅពីរូបភាពខ្លួនឯង រូបភាពមិត្តភ័ក្ត ក្រុមគ្រួសារ ពេលមានការជួបជុំគ្នា ពេលសិក្សា ឬមានកម្មវិធីសំខាន់ៗ ឬក៏កម្មវិធីដើរលេងសប្បាយជុំគ្នាម្តងម្កាលប៉ុណ្ណោះ។

កញ្ញា បានបញ្ជាក់ថា "រឿងនយោបាយ រឿងជេរ រឿងរិះគន់អី គឺខ្ញុំចាំតែមើលគេធេក(Tag) ឬក៏ផេក(Page) ដែលគេ ផ្ញើឲ្យតែប៉ុណ្ណោះ រឿងខ្ញុំទៅសរសេរសារបង្ហោះរឿងនយោបាយអ្វី គឺមិនសោះសូម្បីតែម្តង"។

កញ្ញា បានអះអាងថា ហ្វេសប៊ុកគឺគេអាចធ្វើអ្វីក៏បានដែរ ខ្វះអីគេនិយាយគេសរសេ គេបង្ហោះរូបភាព វីដេអូ ធ្វើនេះធ្វើនោះ រួមទាំងសារនយោបាយតែខ្ញុំខ្ជិល ហើយគិតថា វាអត់ប្រយោជន៍ចាំតែទទួលពីគេទៅបានហើយ។

កញ្ញា បានបន្តទៀតថា "ឃើញគេធេក ឲ្យមក គឺចែករំលែកឲ្យគេវិញខ្លះដែរត្រង់សារ ឬក៏វីដេអូដែលកំប្លែងៗដើម្បីចែកគ្នាសើចសប្បាយ"។

លោក ម៉ឹក សុផានីត ជាយុវនិស្សិតវ័យ ២៣ឆ្នាំ មួយរូបទៀតបានឲ្យដឹងថា ហ្វេសប៊ុក តាមដែលខ្ញុំដឹងគេអាចប្រើបានច្រើនណាស់ ហើយខ្លះរហូតដល់អាចរកចំណូលពីវាបានថែមទៀតផង តាមរយៈការឃោសនាលក់ទំនិញ ហើយនេះគឺជាអ្វីដែលប្អូនធ្លាប់បានធ្វើខ្លះៗជាមួយនិងមិត្តភ័ក្ត។

យុវជន ផានីត បានអះអាងថា ដោយសារនៅក្នុងហ្វេសប៊ុកនេះវាមាន Function( មុខងារ )ច្រើន អ្នកដែលអាចប្រើប្រាស់វាឲ្យមានប្រយោជន៍គឺបានប្រយោជន៍ ពីព្រោះវាងាយស្រួលបង្កើត ងាយស្រួលគ្រប់គ្រង ងាយស្រួលធ្វើកម្មវិធីផ្សេងៗ ដោយសារតែវាអាចផ្សព្វផ្សាយបានទាំង សម្លេង រូបថត វីដេអូ សកម្មភាពបង្ហោះសារ ផ្ញើឯកសារ ដូច្នេះហើយ បើយើងគិតឲ្យដល់វាអាចជាច្រកពាណិជ្ជកម្មបាន។

គិតរហូតមកដល់ពេលនេះ ហ្វេសប៊ុក គឺជាបណ្តាញសង្គមមួយដែលហាក់ដូចជាមានការគាំទ្រពី ប្រជាពលរដ្ឋកម្ពុជាច្រើនជាងគេ និងគ្រប់មជ្ឈដ្ឋាន បើប្រៀបធៀប នឹងអេប(App)បណ្តាញសង្គមផ្សេងៗទៀត។

ហ្វេសប៊ុកពីមុនមក គឺភាគច្រើនអ្នកដែលលេងគឺជាយុវជន ប៉ុន្តែនៅពេលនេះ អ្នកនយោបាយមួយចំនួនរហូតដល់អ្នកកំពូលដឹកនាំនយោបាយដូចជា ប្រធានគណបក្ស កាន់អំណាចដែលកំពុងតែដឹកនាំរាជរដ្ឋាភិបាលគណបក្សនយោបាយប្រឆាំង និងគណបក្សផ្សេងៗទៀតគឺ សុទ្ធតែជាសមាជិកអ្នកគាំទ្រ ហ្វេសប៊ុក។

*ដោយ អរិយបុត្រ*

# យុវជនកំពង់ចាមធ្វើបូជនិយចរស្វែងយល់អំពីទំនាក់ទំនងនិងធម៌មេត្តាករុណា



យុវជនអធិដ្ឋាននៅមុខក្លោងទ្វារដ៏វិសុទ្ធនៅព្រះវិហារសន្តសិលា និងសន្តប៉ូល

លោកបូជាចារ្យ វ៉ូសាំង សេ៉រាល់ និងលោកបូជាចារ្យផាន បូរីបានដឹកនាំក្រុមយុវជនចំនួន៣១នាក់មកពីតំបន់កំពង់-ចាមធ្វើបូជនិយចរនៅទីក្រុងភ្នំពេញស្ថិតក្នុងភូមិភាគភ្នំពេញ គឺចាប់ផ្តើមពីទ្វារដ៏-វិសុទ្ធនៅព្រះវិហារសន្តសិលា និងសន្តប៉ូល ទៅកាន់ទ្វារដ៏វិសុទ្ធទី២ គឺព្រះវិហារសន្តយ៉ូសែប(ផ្សារតូច) និងចុងក្រោយគឺព្រះវិហារព្រះមាតានៃសន្តិភាព (អរិយក្សត្រ)។

ក្នុងដំណើរធម្មយាត្រានេះ ធ្វើឡើងរយៈពេលបីថ្ងៃ គឺចាប់ពីថ្ងៃទី១២-១៤ ឧសភា។ លោកបូជាចារ្យសេ៉រាល់បានបញ្ជាក់ថា ក្នុងថ្ងៃនីមួយៗគឺយុវជនទាំងអស់ត្រូវរិះគិតអំពីជំនឿផង និងទំនាក់ទំនងជាមួយអ្នកដទៃផង។ លោកបូជា-ចារ្យបានមានប្រសាសន៍ទៀតថា "ថ្ងៃទី១ គឺយើងទៅកន្លែងប្រវត្តិសាស្ត្រនានារបស់ព្រះសហគមន៍មុនសម័យប៉ុលពត ថ្ងៃទី២ គឺយើងគិតទៅលើទំនាក់ទំនងជាពិសេសជាមួយអ្នកជំងឺ អ្នកពិការ ឬអ្នកដែលប្លែកពីគេ ហើយនៅថ្ងៃទី៣ គឺទំនាក់ទំនងជាមួយសាសន៍ដទៃ"។

ក្រុមមួយនេះបានធ្វើដំណើរទៅកាន់មណ្ឌលអ្នកជំងឺ និងមណ្ឌលកុមារពិការ ដើម្បីសិក្សាស្វែងយល់ និងទទួលបទពិសោធន៍អំពីធម៌មេត្តាករុណា។

លោកបូជាចារ្យបានបន្ថែមថា "ទំនាក់ទំនង គឺសំខាន់ជាងគេ។ កាលណាយើងនិយាយពីធម៌មេត្តា គឺត្រូវមានទំនាក់ទំនងនៅជាមួយគ្នា"។ តាមការសង្កេតចំពោះយុវជនដែលនៅក្នុងតំបន់របស់លោកទទួលខុសត្រូវ លោកបានមើលឃើញថា ក្នុងក្រុមនេះមានការប្រកាន់ច្រើនមានការបែកបាក់គ្នាដែរ ជួនកាលពួកគេមិនងាយលើកលែងទោសឲ្យគ្នាទៅវិញទៅមកទេ។ លោកសង្ឃឹមថា បូជនិយចរនេះនឹងជួយផ្សះផ្សាទំនាក់ទំនង និងការរិះគិតរបស់យុវជនឲ្យប្រសើរជាងពេលមុន។

លោកបូជាចារ្យសេ៉រាល់ "នៅពេលគេចូលតាមទ្វារប្រៀបដូចជាគេបានចូលទៅក្នុងព្រះបេះដូងព្រះយេស៊ូ។ តាមព្រះយេស៊ូគេចូលទៅក្នុងវិហារ ចូលក្នុងព្រះសហគមន៍ដើម្បីទទួលអំណោយទានជាច្រើន ប៉ុន្តែយើងមិនត្រូវធ្វើជាមនុស្សដែលចេះតែទទួលប៉ុណ្ណោះទេ តែយើងត្រូវចេះផ្តល់ឲ្យគេដែរ"។

លោកបូជាចារ្យរូបនេះបន្តទៀតថា មិនត្រឹមតែចំណុចនេះប៉ុណ្ណោះទេ តែគណៈកម្មាការព្រះសហគមន៍យើងក៏ចង់ឲ្យយុវជនគេមានទំនាក់ទំនងជាមួយបងប្អូនវៀតណាមទាំងក្នុង និងក្រៅព្រះសហ-គមន៍។ លោកបូជាចារ្យបញ្ជាក់ថា "ជាធម្មតាពួកគេអត់សូវជាចូលចិត្តបងប្អូនវៀតណាម ដូច្នេះនៅក្នុងព្រះសហគមន៍យើងមិនអាចទុកឲ្យអារម្មណ៍នេះអណ្តែតទៅឥតចឹង ឬយើងត្រូវទប់ស្កាត់ដើម្បីកុំឲ្យមានបាតុភាព។ ប្រសិនបើនៅពេលណាមានការកាប់សំលាប់គ្នា យើងមិនចង់ឲ្យគ្រីស្តបរិស័ទ និងមនុស្សទាំងអស់ចូលរួមក្នុងការកាប់សម្លាប់គ្នាទេ ជាពិសេសអ្នកដែលខ្ញុំទទួលខុសត្រូវ និងស្គាល់គេ។ ខ្ញុំគិតថា នេះជាការសំខាន់ដែលយើងជួយឲ្យពួកគេចេះរិះគិត អំពីរឿងទំនាក់ទំនងនេះ"។

លោកបូជាចារ្យសេ៉រាល់បានសង្ឃឹមថា ក្រោយពីកម្មវិធីនេះគេមានជំនឿកាន់តែរឹងមាំ ជាពិសេសធម៌មេត្តាករុណារបស់ព្រះយេស៊ូសម្រាប់គេដែលនាំឲ្យគេឃើញព្រះបិតា ហើយនឹងសង្ឃឹមថា នៅក្នុងក្រុមរបស់គេ។ យុវជនដែលមកចូលរួមក្នុងកម្មវិធីនេះមកពី ព្រះសហគមន៍តំបន់កំពង់ចាមចំនួន ៤ភូមិ គឺកោះរការ ផ្កាដូង ថ្មពេជ្រ និងសួង។

*កញ្ញា*

## ច្បាប់ចរាចរណ៍ ផ្លូវគោកថ្មី

**សង្ខេតមាត្រ២៩៖**

អត្ថន័យនៃភ្លើងសញ្ញាពិសេស៖

o ពណ៌ខៀវឬក្រហម សម្រាប់យានអាទិភាពដូចជា យានពន្លត់អគ្គិភ័យ សង្គ្រោះរបស់មន្ទីរពេទ្យ នគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចណ៍ផ្លូវគោកនាំមុខ.....។

o ពណ៌លឿងទុំ ត្រូវប្រើសម្រាប់យានបម្រើការងារសាធារណៈ។ យានដែលបំពាក់ភ្លើងសញ្ញានេះ គឺបើកបរក្នុងល្បឿនយឺត។ ពេលឃើញភ្លើងពណ៌នេះត្រូវប្រុងប្រយ័ត្នក្នុងការជៀស ឬជែងយានទាំងនោះ។

o នៅពេលជួបយានមានសិទ្ធិអាទិភាព អ្នកបើកបរត្រូវបន្ថយល្បឿនអែបស្តាំ ឬឈប់ដើម្បីអាទិភាពឲ្យយានទាំងនោះ ឆ្លងកាត់ដោយស្រួល។

o យានអាទិភាពមានសិទ្ធិ៖

- បញ្ច្រាសទិសនៅលើផ្លូវឯកទិស
- នៅពេលភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺពណ៌ក្រហម

o ក្នុងល្បឿនមិនកំណត់

o ដោយមានសិទ្ធិអាទិភាពលើផ្លូវប្រសព្វ

o កាត់ឬជាន់ខ្សែគំនូសបង្ហូតជាប់។

ទោះជាយ៉ាងណាក៏ដោយ អ្នកបើកបរយានប្រភេទនេះត្រូវបើកបរដោយប្រុងប្រយ័ត្នជានិច្ច ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត និងត្រូវគោរពសញ្ញាបញ្ជាដោយភ្នាក់ងារចរាចរណ៍ជាដាច់ខាត។

**មាត្រា៣២៖**

ក្បួនដង្ហែផ្សេងៗនិងការប្រើប្រាស់ផ្លូវសម្រាប់គោលបំណងផ្សេងទៀតដែលមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវគោរពតាមការណែនាំដូចខាងក្រោម៖

ក-ក្បួនដង្ហែផ្សេងៗ៖

o ត្រូវហែនៅអែបទ្រូងផ្លូវខាងស្តាំតាមទិសចរាចារណ៍ ហើយត្រូវទុកទ្រូងផ្លូវផ្នែកខាងឆ្វេងឲ្យនៅទំនេរទាំងស្រុង

o អាចដើរហែក្បួនជាពីរ បីឬបួនជួរបាន ដោយប្រមាណដល់ទទឹងទ្រូងផ្លូវហើយត្រូវគោរពបទបញ្ជាចរាចរណ៍

o ត្រូវកាន់ភ្លើងពណ៌សនៅខាងមុខ និងត្រូវកាន់ភ្លើងពណ៌ក្រហមនៅខាងក្រោយនៅពេលយប់ ឬពេលថ្ងៃកាលណាមើលមិនឃើញច្បាស់គ្រប់គ្រាន់។

ខ-ការប្រើប្រាសផ្លូវសម្រាប់គោលបំណងផ្សេងទៀតតាមការចាំបាច់អាចអនុញ្ញាតឲ្យបានតាមការកំណត់នៃប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រ-សួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

# មេធាវី៖ ច្បាប់នៅកម្ពុជាអាចបង្ករការលំបាកសម្រាប់អ្នកក្រីក្រនៅពេលមានវិវាទឈានដល់តុលាការ

ស្ថាប័នតុលាការ ត្រូវបានគេដឹងថាគឺជាចំណុចរសើបមួយនៅក្នុងសង្គមកម្ពុជា ហើយចំពោះពលរដ្ឋសាមញ្ញទូទៅឲ្យតែមានបញ្ហាដែលពាក់ព័ន្ធនឹងតុលាការគឺនាំគ្នាខ្លាចរអែង ដូច្នេះនៅក្នុងថ្ងៃនេះ ដើម្បីជាចំណេះដឹង ជូនដល់ប្រជាពលរដ្ឋ កាសែតអ្នកនាំសារសូមណែនាំជូនលោកអ្នកអាន ឲ្យជួបជាមួយនឹងលោក សុខ សំអឿន នៅក្រុមអ្នកច្បាប់អមរិន្ទ ។



អ្នកនាំសារៈ ៖ នៅពេលដែលប្រជាពលរដ្ឋសាមញ្ញមួយរូបមានបញ្ហានឹងផ្លូវច្បាប់ តើជំហានដំបូងពួកគាត់ ត្រូវធ្វើដោយរបៀបណា ?

លោក សុខ សំអឿន ៖ ជាធម្មតាកាលណាដែលយើងមានបញ្ហាហើយយើងមិនសូវចេះច្បាប់នោះជាបញ្ហាលំបាកបន្តិច ដូច្នេះយើងគួរតែទៅរកសេវាច្បាប់ពីមេធាវីដែលគេមានជំនាញ ។

អ្នកនាំសារៈ នៅក្នុងប្រព័ន្ធច្បាប់ស្រុកយើង តើប្រជាពលរដ្ឋត្រូវមានរឿងក្តីក្តាំកម្រិតណាទើបគួរទៅរក មេធាវី ?

លោកសុខ សំអឿន ៖ កាលណាយើងមានបញ្ហាយើងត្រូវគិតមើលថា តើយើងត្រូវខាតបង់ទ្រព្យសម្បត្តិដែរ ឬអត់ ។ តាមធម្មតាកាលណាគេប្តឹងយើង គឺចង់ទាមទារអ្វីមួយពីយើង ដូច្នេះបើយើងមិនត៉វ៉ា មិនអីទេ គឺយើងត្រូវខាតបង់ទៅតាមអ្វីដែលគេទាមទារ ។

អ្នកនាំសារ៖ ចុះប្រសិននោះ គឺជាករណីដែលកើតមានឡើងចំពោះប្រជាជនដែលក្រីក្រ តើគាត់គួរធ្វើយ៉ាងណា ?

លោក សុខ សំអឿន ៖ ប្រសិនបើគាត់ គឺជាអ្នកដែលក្រីក្រ នោះគឺជារឿងមួយដែលពិបាក ពីព្រោះច្បាប់របស់យើងគឺយើងយកតាមជប៉ុន ដែលមានជីវភាពមួយធូធារ ដូច្នេះយើងអាចមានបញ្ហា។ តាមច្បាប់តុលាការគឺអកម្ម ដូច្នេះតុលាការគេអត់ខ្វល់ពីអ្វីទេ សំខាន់គឺថា ភាគីទាំងពីរផ្តល់ភស្តុតាងដាក់ទៅ ដូច្នេះបើយើងអត់យកអ្នកច្បាប់ទៅទេ គឺយើងអាចមានបញ្ហា ។

អ្នកនាំសារ៖ តើនៅស្រុកយើងនៅពេលបច្ចុប្បន្ននេះអាចមានអង្គការក្រៅរដ្ឋាភិបាល ឬក៏ស្ថាប័នណាដែលអាចនឹងផ្តល់ជំនួយផ្នែកច្បាប់នេះទៅដល់ពួកអ្នកក្រីក្រដែរឬទេ ?

លោក សុខ សំអឿន ៖ កាលពីមុនគឺមាន ដូចអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិប្រជាជនកម្ពុជាដែល ខ្ញុំជាប្រធានហ្នឹង យើងមានថវិការ ឬសកម្មភាពដើម្បីជួយដល់អ្នកក្រីក្រ ប៉ុន្តែឥឡូវវាអស់ហើយ។ ជាពិសេស គឺរឿងរដ្ឋប្បវេណី គឺអត់តែម្តង ដោយម្ចាស់ជំនួយគេលែងសូវផ្តោតទៅលើកម្មវិធីជំនួយបែបហ្នឹង។ គេនៅមាន ប៉ុន្តែវាតិចតួច ដែលពាក់ព័ន្ធនឹងរឿងដីធ្លីធំៗ បានមានអង្គការមួយចំនួន គាត់ជួយ ហើយដូចអង្គការខ្ញុំ គឺអស់មូលនិធិប្រហែលជា ៤ ឆ្នាំមកហើយ។

អ្នកនាំសារៈ តើមូលហេតុអ្វីបានជាគេមិនយកចិត្តទុកដាក់លើបញ្ហាជំនួយផ្នែកច្បាប់នេះ ដល់ពលរដ្ឋក្រីក្រ ?

លោក សុខ សំអឿន ៖ បញ្ហាទីមួយគឺអាចថា ថវិការបស់ម្ចាស់ជំនួយគាត់ចុះខ្សោយ។ ដូច្នេះដល់តែគេចុះខ្សោយទៅ គេត្រូវគិតថា លុយគេមានតិចតួចនេះ តើត្រូវផ្តល់ទៅលើអ្វីដែលជាអាទិភាព ? ។ ហើយអាចដោយសារតែ គេមើលទៅប្រព័ន្ធតុលាការនៅស្រុកយើងរាងរឹងមាំបន្តិច ដែរដល់ឥចឹងគេក៏កាត់បន្ថយ។

អ្នកនាំសារ៖ សម្រាប់អ្នកដែលមានរឿងក្តីក្តាំតាមផ្លូវតុលាការនេះ ឥឡូវតើលោកដឹងថា នៅសល់អង្គការក្រៅរដ្ឋាភិបាលប៉ុន្មានដែលអាចផ្តល់សេវាកម្មនេះដល់អ្នកដែលក្រីក្រ ?

លោក សុខ សំអឿន ៖ គឺហាក់ដូចជាមានតិចណាស់ស្ទើរតែអត់ហ្មង។ បើមាន គឺមានតែរឿងដីធ្លីខ្លះដែលធំៗប្រហែលជាមានដូចជា អាដហុក លីកាដូ ពីរបីដែលធំៗ ហើយក្រៅពីនោះ បើសិនជារឿងពាក់ព័ន្ធ និងស្ត្រីអាចនៅសល់អង្គការច្រើន។

អ្នកនាំសារ ៖ តើនៅពេលដែលលោកនៅបម្រើការនៅអង្គការក្រៅរដ្ឋាភិបាល តើកម្រិតនៅការជួយពលរដ្ឋនោះ ត្រឹមកម្រិតណាដែរ ?

លោក សុខ សំអឿន ៖ ខ្ញុំនិយាយអំពីពេលដែលមានមូលនិធិពេញបន្ទុក គឺអង្គការដែលខ្ញុំបម្រើការ គឺមានទាំងរដ្ឋប្បវេណី និងព្រហ្មទណ្ឌចាប់ពី ១០០០ទៅ ២០០០ ក្តីនៅក្នុងមួយឆ្នាំ។ តែបើរឿងរដ្ឋប្បវេណី រឿងដីធ្លី គឺមានប្រមាណជា ៦០ ភាគរយ។ ក្រៅពីនោះគឺជារឿងស្ត្រី។

អ្នកនាំសារ ៖ តើនៅក្នុងស្ថានភាពដូចសព្វថ្ងៃនេះ តើពលរដ្ឋក្រីក្រ គាត់ត្រូវជួបប្រទះនូវបញ្ហាធ្ងន់ធ្ងរយ៉ាងណានៅក្នុងករណីមានបន្តឹង ?

លោក សុខ សំអឿន ៖ បើសិនជាក្រីក្រគឺដឹងថា គឺត្រូវតែចាញ់គេតែម្តង។ បើសិនជាយើងដឹងថា គេប្តឹងយើងចង់បានដីហើយ គឺមានតែសុំចរចារសុំលុយគេតិចតួចវិញទៅ ប្រសើរជាត៉វ៉ាក្តី។ តាមច្បាប់យើងគឺថា អ្នកក្រពិបាកនឹងប្តឹងគេណាស់។ ពីព្រោះបើយើងចង់ប្តឹងគេគឺត្រូវបង់ពន្ធ។ ឧទាហរណ៍គេប្តឹងយើងទៅសាលាដំបូង គេប្តឹងយើងនោះគេបង់ តែដល់គេឈ្នះ យើងចង់ឧទ្ធរណ៍នោះ យើងត្រូវបង់ដល់ចឹងទៅ អ្នកក្រ គឺពិបាក នោះមិនទាន់និយាយដល់សេវាមេធាវីទេ ការដែលនិយាយត្រូវបង់ពន្ធទៅតុលាការនោះ គឺយ៉ាប់តែម្តង ដូច្នេះមានវិធីមួយ គឺសុំចាញ់ ហើយអង្វរគេទៅបើគេជាអ្នកធំហើយនោះ។

អ្នកនាំសារ៖ តើតម្លៃនៃការចំណាយរឿងក្តីដ៏តូចមួយ គិតចាប់ពីតម្លៃសេវាកម្មមេធាវី ពន្ធផ្សេងៗ តើមួយចប់ក្តីមានតម្លៃប៉ុន្មានដែរ ?

លោក សុខ សំអឿន ៖ បើយើងនិយាយអំពីពន្ធ គឺគេគិតតាមកម្មវត្ថុបន្តឹង ឧទាហរណ៍គេប្តឹងទារដីយើង ដីយើងមានតម្លៃត្រឹមតែ ១០.០០០ ដុល្លារ ឥចឹង គេគិតតាមភាគរយនោះ។ តាមកម្មវត្ថុ តែបើនិយាយអំពីមេធាវី គឺអាស្រ័យលើបុគ្គលមេធាវីម្នាក់ៗ។ កន្លងមក គឺអាចមានបញ្ហាខ្លះដែរ មេធាវីខ្លះ គាត់ថាយកតិច ប៉ុន្តែគាត់ចិញ្ច្រាំលើសេវាផ្សេងៗទៀតដល់ចឹងទៅគឺច្រើន ហើយមេធាវីខ្លះគឺគេគិតមួយក្តីតែម្តងឧទាហរណ៍ មួយក្តីនៅសាលាដំបូងជាដើម។

អ្នកនាំសារ ៖ ជាមធ្យមតម្លៃមេធាវីនៅក្នុងមួយរឿងក្តីតម្លៃប៉ុន្មានដែរ ?

លោក សុខ សំអឿន ៖ និយាយថោកបំផុតជាពិសេសគឺអ្នកក្រ យ៉ាងហោចណាស់ក៏ ៥០០ដែរ បានអាចធ្វើរឿងក្តីមួយបាន។ ហើយមេធាវីនេះបានថ្លៃគុយទាវ កាហ្វេខ្លះ ពីព្រោះថា រឿងក្តីខ្លះមិនមែនធ្វើតែម្តងចប់ទេ គឺត្រូវចុះឡើងតុលាការញឹក ដូច្នេះប៉ុណ្ណឹងមិនបានប៉ុន្មានទេ។ តម្លៃនេះ គឺវាតិចទេតែដល់អ្នកក្រ គាត់មើលអាហ្នឹងវាធំណាស់ សម្រាប់គាត់ ដូច្នេះហើយបានជាខ្ញុំនិយាយថា កាលណាក្រ គឺពិបាកហើយ។

អ្នកនាំសារ ៖ ចុះតម្លៃសេវា មេធាវី ថាតើនៅសាលាដំបូងប៉ុន្មាន ? ដល់សាលាឧទ្ធរណ៍ ដល់តុលាការកំពូល តើតម្លៃយ៉ាងណាដែរ ?

លោក សុខ សំអឿន ៖ តម្លៃនេះវាមិនទៀងទេ ឧទាហរណ៍ថា គាត់ជាកូនក្តីរបស់ខ្ញុំ បើខ្ញុំកាន់ក្តីនេះ តាំងពី សាលាដំបូង រហូតដល់តុលាកាកំពូល ខ្ញុំអាចចុះថ្លៃឲ្យ ដោយសារអី គឺខ្ញុំដឹងសាច់រឿងអស់ហើយ ប៉ុន្តែបើរឿងនោះថ្មីនោះវាអាចថ្លៃ ដោយសារតែត្រូវសិក្សា ស្វែងយល់រឿងក្តីនេះច្រើន។

អ្នកនាំសារ ៖ ដោយសារតែលោកមានទំនាក់ទំនងនឹងអ្នកក្រ តាំងពីលោកបម្រើការនៅអង្គការក្រៅរដ្ឋាភិបាលមក តើប៉ុន្មានភាគរយនៃអតិថិជនរបស់លោកជាអ្នកក្រីក្រ ?

លោក សុខ សំអឿន ៖ កូនក្តីរបស់ខ្ញុំភាគច្រើនគឺជាអ្នកក្រ។ ទីមួយអ្នកក្រទៅមេធាវីផ្សេងគឺថ្លៃ តែខ្ញុំដោយសារតែខ្ញុំធ្លាប់នៅអង្គការ សិទ្ធិមនុស្ស ឥចឹងដល់ឃើញគ្នា ក្រីក្របែបនេះ គឺមិនដឹងជាត្រូវទៅយកអីឲ្យថ្លៃពីពួកគាត់ទៀត។ ហើយកាលណាខ្ញុំជួយគឺខ្ញុំជួយម៉ាអស់ពីចិត្តពីថ្លើម ហើយជួយមួយសាលាក្តី។

*ដោយអរិយបុត្រ*

# កម្មករនិងកម្មការនីរោងចក្រកាត់ដេរនិយាយថា សហជីពពិតជាមានតួនាទីសំខាន់សម្រាប់ពួកគេ



*សហជីពកម្មករកម្ពុជាបានជូនលុយដល់កម្មករឈឺវះកាត់ស្បូន*

កម្មករនិងកម្មការនីរោងចក្រកាត់ដេរមួយចំនួននៅក្នុងទីក្រុងភ្នំពេញអះអាងថា សហជីពពិតជាសំខាន់សម្រាប់ពួកគេ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនបានតាមដានចំពោះ ព័ត៌មានជុំវិញការវិវត្តន៍នៃច្បាប់សហជីពឡើយ។

កញ្ញា ជិន សុនេត្រា ជាកម្មកររោងចក្រកាត់ដេរនៅម្ដុំរោងចក្រកាត់ដេរនៅគីឡូម៉ែត្រលេខ ៦ បានអះអាងថា សហជីពគឺពិតជាសំខាន់សម្រាប់កម្មករដោយសារតែសហជីពនេះបានជួយច្រើនដល់ បងប្អូនកម្មករនិងកម្មការនីទាំងឡាយ។

កញ្ញា បានបញ្ជាក់ថា "អារឿងយើងឡើងប្រាក់ខែគោល អាលុយថែមម៉ោង អារឿងសុខមាលភាព រឿងបណ្ដេញកម្មករអីហ្នឹង បើអត់មានសហជីពទេស្រេចតែរដ្ឋបាលរោងចក្រ និងថៅកែជាអ្នកថា ហើយពួកគេចង់កាត់ ចង់ដេញ ចង់បន្ថែមការងារ បន្ថែមម៉ោងស្រេចតែចិត្ត"។

កញ្ញា បន្តទៀតថា "បើតាមខ្ញុំយល់ សហជីព គឺជាតំណាងឲ្យខ្ញុំ និងកម្មករកម្មការនីរោងចក្រទាំងអស់"។

កញ្ញា បានបន្តទៀតថា ខ្ញុំធ្លាប់បានធ្វើការនៅរោងចក្រ៣ ទៅ៤ រោងចក្រហើយ បើកាលណារោងចក្រណា មានតំណាងសហជីពល្អ យើងខ្ញុំក៏ទទួលបានភាពកក់ក្ដៅទៅតាមនោះ ដោយសារតែប្រធានសហជីពខ្លះគាត់ចេះ ធ្វើការជាមួយកម្មករ ចេះធ្វើការជាមួយថៅកែ ហើយក៏ចេះដឹងអំពីទុក្ខធុរៈយើងជាកម្មករ ដូច្នេះរវាងពួកយើង គឺមានផលប្រយោជន៍ បរិយាកាសការងារក៏ប្រសើរ។

កញ្ញា បន្តថា ដូចខ្ញុំឥចឹងកាលពីធ្វើការនៅរោងចក្រមុន ខ្ញុំសន្លប់បើកុំតែបានពូសហជីពនោះរឹងមាំតវ៉ាដល់ថៅកែទៅទើបមានការដោះស្រាយរឿងថ្លៃព្យាបាល និងពេលសម្រាកគ្រប់គ្រាន់ កុំអីខ្ញុំយ៉ាប់"។

នេះគឺជាសំដីរបស់យុវកម្មការនីរោងចក្រម្នាក់ ដោយឡែក លោក ជុំ សេដ្ឋា ជាកម្មករនៅរោងចក្រ ខោខូវប៊ិយមួយនៅម្ដុំទួលសង្កែ ក៏បានទទួលស្គាល់អំពីតួនាទីរបស់សហជីពនៅកន្លែងគាត់ធ្វើការ។

លោក បានអះអាងថា សហជីពខ្លះចេះតែថា អត់បានការអត់សកម្មភាព ប៉ុន្ដែទីកន្លែងធ្វើការមួយ ដែលអត់មានសហ-ជីព គឺស្រេចតែថៅកែថាទេ។

លោកអះអាងបញ្ជាក់ថា "នរណាថាសហជីពអត់បានការ គឺជារឿងរបស់គេ តែខ្ញុំយល់ថា សំខាន់ ហើយបើអត់សហ-ជីពវិញនោះ មិនដឹងជាកម្មករត្រូវថៅកែរដ្ឋបាលជិះជាន់យ៉ាងណាទេ។ រាល់ថ្ងៃនេះបានពួកសហជីពទេ ដែលជួយការពារ"។

លោកបានបញ្ជាក់ថា "ជាទូទៅបើអត់សហជីពទេ ថៅកែមិនសូវខ្លាច និងយកចិត្តទុកដាក់កម្មករទេ តែដល់មានសហជីពមកពួកគេរាងញញើតបន្តិចដែរ"។

លោកបន្តទៀតថា កន្លងមកអ្នកខ្លះថា សហជីពអត់ល្អអត់ប្រយោជន៍ ចេះតែនាំកម្មករធ្វើបាតុកម្មអត់ព្រមធ្វើការតែតាមពិតនោះគឺគ្រាន់តែជាការនិយាយទេ។

កញ្ញា វ៉េត ចាន់ណា ជាយុវតីកម្មការនីរោងចក្រកាត់ដេរនៅសួនឧស្សាហកម្មកាណាឌីយ៉ា បានរំលឹកថា នៅមុនពេលចូលមកបម្រើការងារនៅសួនឧស្សាហកម្មនេះ កញ្ញាធ្លាប់ធ្វើការនៅរោងចក្រមួយនៅកំពង់ស្ពឺ ដែលរដ្ឋបាលថា ថៅកែក្ស័យធនអត់បើកប្រាក់ខែឲ្យ ប៉ុន្ដែសំណាង មានសហជីព ដឹកនាំការតវ៉ា ក៏មានអន្តរាគមន៍បើកប្រាក់ខែ និងប្រាក់បំណាច់បានមួយចំនួន មុនពេលចែកផ្លូវគ្នា ដើររកការងារធ្វើផ្សេងៗគ្នាដល់បច្ចុប្បន្ននេះ។

នេះគឺជាសម្លេងរបស់កម្មករនិងកម្មការនីរោងចក្រកាត់ដេរដែលបាននិយាយអំពីតួនាទីរបស់សហជីព ប៉ុន្ដែទោះបីជាយ៉ាងណាក៏ដោយ ពួកគេហាក់មិនបានតាមដានអំពីការវិវត្តន៍ចុងក្រោយរបស់សហជីព ជាពិសេសគឺការអនុម័តនូវច្បាប់សហជីពនេះពីសំណាក់រដ្ឋសភា និងព្រឹទ្ធសភានៅឡើយ។

ជុំវិញរឿងច្បាប់សហជីព កញ្ញា វ៉េត ចាន់ណាបានអះអាងថា អត់បានសូវតាមដានព័ត៌មានផង ដូច្នេះ មិនសូវដឹងទេ។

កញ្ញា បានបញ្ជាក់ថា "ខ្ញុំឮតែគេថាមានច្បាប់ មានអី តែ វាអស់កម្លាំងពេលមកដល់ផ្ទះ មុជទឹក ញ៉ាំបាយញ៉ាំអីហើយខ្ញុំចូលគេងហើយ"។

អ្វីដែល ចាន់ណា និយាយគឺមិនខុសពីសំដីរបស់លោកសេដ្ឋា និងកញ្ញាសុនេត្រា។ ជាទូទៅកម្មករ និងកម្មការនីភាគច្រើនមិនសូវជាយកចិត្តទុកដាក់នៅក្នុងការស្ដាប់តាមដាន ព្រឹត្តិការណ៍ព័ត៌មានផ្សេងៗឡើយ។ ម្នាក់ៗគឺគិតតែពីធ្វើការគេងកំសាន្ត លេង តែប៉ុណ្ណោះ ប៉ុន្ដែខ្វះខាតការយកចិត្តទុកនឹងបញ្ហាដែលនៅជុំវិញខ្លួន ។

ទាំងនេះជាសម្លេងមួយដែលនិយាយអំពីតួនាទីនិងសារៈសំខាន់របស់សហជីពតាមរោងចក្រឧស្សាហកម្ម ប៉ុន្ដែទោះបីជាយ៉ាងណាក៏ដោយ កាលពីថ្ងៃទី០៤ មេសា សមាជិករដ្ឋសភាបានប្រជុំពិភាក្សានឹងអនុម័តពង្រាងច្បាប់នេះ ហើយអនុម័តជាស្ថាពរដោយតំណាងរាស្ត្រមកពីគណ-បក្សកាន់អំណាច។

ពង្រាងច្បាប់ដែលមាន ១០០ មាត្រា និង១២ជំពូក ត្រូវបានអនុម័តម្ដងមួយជំពូកៗក្រោមសំណួរ ជាបន្តបន្ទាប់ដោយសមាជិកសភាមកពីគណបក្សប្រឆាំង។

បន្ទាប់ពីច្បាប់នេះឆ្លងរដ្ឋសភា លោក សុន ឆ័យ សមាជិកសភា មកពីគណបក្សសង្គ្រោះជាតិ មានប្រសាសន៍ថា ការដែលគណបក្សប្រឆាំងមិនគាំទ្រ គឺមិនមែនចង់ចំណេញនយោបាយទេ គឺដោយសារតែខ្លឹមសារនៃច្បាប់នេះ មិនបានដាក់បញ្ចូលនូវអ្វីដែលសហជីពបានទាមទារ។

ជុំវិញការរិះគន់របស់គណបក្សប្រឆាំង លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងយុវនិតិសម្បទាបានថ្លែងថា ការដាក់ចេញនូវច្បាប់នេះ គឺជាដើម្បីជាការធានាខ្សែសង្វាក់ការងារល្អ រវាងកម្មករ និងថៅកែ។

លោកបានបញ្ជាក់ថា ច្បាប់នេះ នឹងជួយធានាឲ្យកម្ពុជា ទទួលបាននូវការធានាសេរីភាពពីអង្គការវិជ្ជាជីវៈ និងសុខ-ដុមនីយកម្ម ក្នុងទំនាក់ទំនងពាណិជ្ជកម្មដែលជាកត្តាស្នូលនៃ ស្ថិរភាពខ្សែរ សង្វាក់ផលិតកម្ម និងការទាក់ទាញវិនិយោគនៅក្នុងកម្ពុជានាពេលបច្ចុប្បន្ន។

បន្ទាប់ពីឆ្លងកាត់រដ្ឋសភា ពង្រាងច្បាប់សហជីពនេះ ក៏ត្រូវបានសមាជិកព្រឹទ្ធសភាចំនួន៤០ លើ៤៦ រូប គាំទ្រនិងអនុម័តពង្រាងច្បាប់នេះយ៉ាងជោគជ័យ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦នេះ។

កន្លងមកមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាអះអាងថា កម្ពុជាគឺជាឋានសួគ៌ានៃអង្គ-ការក្រៅរដ្ឋាភិបាល និងសហជីពដ៏ច្រើន។

*ដោយ អរិយបុត្រ*

# អង្គការសង្គមស៊ីវិល៧៧រិះគន់ស្ថានភាពសិទ្ធិមនុស្សកម្ពុជា

តាមក្រុមបណ្ដាញអង្គការសង្គមស៊ីវិលចំនួន៧៧ បានរួបរួមគ្នាសំដែងការមិនពេញចិត្តចំពោះការវិវត្តន៍ចុងក្រោយនៃស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយក៏បានស្នើសុំឲ្យមានការធានាជាថ្មីថា សិទ្ធិនិងសេរីភាពជាមូលដ្ឋាននានា របស់អ្នកការពារសិទ្ធិមនុស្សក្នុងការងាររបស់ពួកគេដោយសេរីជៀសផុតពីការបំភិតបំភ័យនិងជាក់ទណ្ឌកម្ម ។

ការរិះគន់និងការស្នើសុំនេះគឺបានកើតមានឡើងក្រោយពេល ដែលអាជ្ញាធរកម្ពុជាបានចាប់ខ្លួនអ្នកការពារសិទ្ធិក្នុងយុទ្ធនាការពាក់អាវពណ៌ខ្មៅ កាលពីពេលថ្មីៗនេះ។

លោកស្រី ណាលី ពីឡូ នាយិកាអង្គការលីកាដូ បានលើកឡើងក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី១០ ឧសភា ២០១៦ ថា ការឃាត់ខ្លួននេះ គឺជាការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ដែលមិនត្រឹមត្រូវ ដើម្បីបំភិតបំភ័យលើសមាជិកសង្គមស៊ីវិល។

លោក អ៊ុំ សារ៉ុម នាយកប្រតិបត្តិ នៃសមាគមជាងឆ្នោត ក៏បានលើកឡើងក្នុងសេចក្តីថ្លែងការណ៍នោះផងដែរថា ចំណាត់ការរបស់អាជ្ញាធរ គឺជាការអស់សំណើច។ យុទ្ធនាការ ពាក់អាវពណ៌ខ្មៅនេះគឺ គ្រាន់តែជាការសំដែងមតិដោយអហិង្សា អំពីការមិនពេញចិត្តរបស់ពួកយើងប៉ុណ្ណោះ។

សេចក្តីថ្លែងការរបស់បណ្តុំនៃអង្គការសង្គមស៊ីវិលនេះគឺត្រូវបានធ្វើឡើងក្រោយពេលដែល អាជ្ញាធរបានចាត់វិធានការលើអ្នកចូលរួមក្នុងយុទ្ធនាការ អាវខ្មៅ ៣០០នាក់ ដែលបានទាមទារឲ្យដោះលែងមន្ត្រីអាដហុក៤នាក់ និងលោក នី ចរិយា អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

# អគ្គរាជទូតកម្ពុជាមួយរូបទៀតជួបប្រទះរឿងអាស្រូវ

ក្រោយពេលដែលអគ្គរាជទូតកម្ពុជាប្រចាំនៅសាធារណៈរដ្ឋកូរ៉េ ត្រូវបានអង្គភាពប្រឆាំងនឹងអំពើ ពុករលួយចោទប្រកាន់ និងឃុំខ្លួនពីបទប្រព្រឹត្តអំពើពុករលួយ លោកកុយ គួង ឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅប្រទេសអូស្ត្រាលី ក៏កំពុងតែជួបរឿងអាស្រូវមួយករណីទៀត។

រឿងអាស្រូវនេះ ត្រូវបានបែកធ្លាយក្រោយពេលដែលកាសែត ស៊ីដនី ម៉នីង ហេរ៉ាល របស់អូស្ត្រាលី ចុះផ្សាយនូវអត្ថបទមួយថា មន្ត្រីទូតកម្ពុជា និងបរទេសផ្សេងទៀត គឺអាចជាប់ពាក់ព័ន្ធនឹងករណីជួញដូរគ្រឿងស្រវឹង និងបារី នៅក្នុងទីផ្សារងងឹតនៅអូស្ត្រាលី។

ជុំវិញបញ្ហានេះ លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស បានប្រាប់អ្នកសារព័ត៌មានថា ក្រសួងកំពុងរង់ចាំចម្លើយពីលោកកុយគួងជុំវិញបទសង្ស័យនេះ។

ការចុះផ្សាយរបស់កាសែតអូស្ត្រាលីខាងលើបានបន្តឲ្យដឹងថា សម្រាប់មន្ត្រីទូតម្នាក់ដែលមានបេសកម្មនៅអូស្ត្រាលី គឺអាចនាំចូលស្រាបៀ ៥០០លីត្រ ស្រា ១២០លីត្រ និងបារីប្រមាណជាជាង ១០.០០០ដើម នៅក្នុងរយៈពេល ២ឆ្នាំ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ។

# ក្រសួងបរិស្ថាន៖ តំបន់ការពារធម្មជាតិនៅកម្ពុជានៅពេលនេះមាន៤១ កន្លែង

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខារួចហើយលើអនុក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិចំនួន ១៨ ដែលមានផ្ទៃដីសរុបចំនួន ២ ៦៧៤ ៥០៣ ហិកតា។

ក្រសួងបរិស្ថានបានឲ្យដឹងថា តំបន់ទាំង១៨ កន្លែងនេះ គឺនឹងស្ថិតក្រោមការគ្រប់គ្រង និងអភិរក្សរបស់ក្រសួង ។

ប្រភពដដែលបានឲ្យដឹងថា តំបន់ការពារធម្មជាតិទាំងនោះ គឺមានតំបន់ព្រៃការពារ និងអភិរក្សព្រៃឈើចំនួន១៣ កន្លែង និងព្រៃផ្តល់ផលចំនួន ៥កន្លែង ក្នុងនោះក៏មានព្រៃឡង់ផងដែរ។

ប្រភពដដែលបានបន្តថា តំបន់ការពារធម្មជាតិនេះទើបតែត្រូវបានរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្ទេរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមកឱ្យក្រសួងបរិស្ថានធ្វើការគ្រប់គ្រង និងអភិរក្ស។

រហូតមកដល់ពេលនេះ ជារួមក្រសួងបរិស្ថាន មានតំបន់ការពារធម្មជាតិសរុបចំនួន ៤១ ដែលមានផ្ទៃដីសរុបចំនួន ៥.៨៧៤.៥០៣ ហិកតា រួមបញ្ចូលទាំងតំបន់ការពារធម្មជាតិដែលក្រសួងបរិស្ថានមានស្រាប់តាំងពីឆ្នាំ១៩៩៣ មកចំនួន២៣ ដែលមានផ្ទៃដីចំនួន ៣,២លានហិកតា។

# លោក បារ៉ាក អូបាម៉ា មកបំពេញទស្សនកិច្ចនៅក្នុងប្រទេសវៀតណាម មុនបញ្ចប់អាណត្តិ

លោកប្រធានាធិបតីអាមេរិក បារ៉ាក អូបាម៉ា ធ្វើដំណើរមកប្រទេសនៅអាស៊ីអាគ្នេយ៍ជាថ្មី នៅមុនពេលលោកបញ្ចប់អាណត្តិប្រធានាធិបតីរបស់លោក។

មន្ត្រីក្រសួងការបរទេសអាមេរិកបាននិយាយកាលពីខែឧសភាថា នៅក្នុងអំឡុងពេលទស្សនកិច្ចនៅវៀតណាម លោក និងសមភាគីវៀតណាម បានផ្តោតការពិភាក្សាគ្នា អំពីពាណិជ្ជកម្ម សន្តិសុខ និងសិទ្ធិមនុស្ស។

របៀបវារៈទាំងនេះ គឺស្ថិតក្នុងរបៀបវារៈកំពូលនៅពេលលោកបារ៉ាក អូបាម៉ាបំពេញទស្សនកិច្ចនៅវៀតណាម។

អ្នកវិភាគបានអះអាងថា ដំណើរទស្សនកិច្ចនេះ គឺបានធ្វើឡើងនៅក្នុងអំឡុងពេលដែល សភាពការណ៍នៅសមុទ្រចិនខាងត្បូងកំពុងតែកើនឡើងនូវកំដៅ ក្រោយពេលដែលនាវាអាមេរិកមួយគ្រឿង បានបើកចូលទៅជ្រៅ ក្នុងតំបន់ដែលចិនបានអះអាងថា គឺជាដែនអធិបតេយ្យរបស់ខ្លួន។

គួររំលឹកផងដែរថា នៅចុងអាណត្តិនេះលោក ប្រធានាធិបតី បារ៉ាក អូបាម៉ា បានធ្វើដំណើរទស្សនកិច្ច នៅប្រទេសដែលជាអតីតគូសត្រូវនិងគ្នា ហើយជាបន្តបន្ទាប់ដោយលោកបានទៅទស្សនកិច្ចនៅប្រទេសគុយបា និងមកវៀតណាម ដែលជាអតីតសត្រូវក្នុងសម័យសង្គ្រាមវៀតណាម។

លោក ដានីញែល រូសសែល ឧបការីក្រសួងការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិច បាននិយាយថា ចំណាត់ការដកបម្រាមលក់សព្វាវុធ គឺជាការសម្រេចចិត្តជាមួយវៀតណាម ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការណ៍នៅក្នុងតំបន់។

## ប្រមុខរដ្ឋាភិបាលគ្រោងជួបគ្រីស្តបរិស័ទ

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី០៦ មិថុនា បានមានប្រសាសន៍ថា សម្តេចគ្រោងជួបគ្រីស្តបរិស័ទនៅកម្ពុជាម្តង ។

នៅក្នុងពិធីអញ្ជើញកាត់ ឫសសីម៉ាព្រះវិហារវត្តមឿងចារលិខិតារាមស្ថិតនៅក្នុងឃុំជាំងទងស្រុកត្រាំកក់ ខេត្តតាកែវ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា នៅថ្ងៃទី១៤ ខែមិថុនាខាងមុខ សម្តេចនឹងអញ្ជើញចូលរួមពិធីស្រាយបួសជាមួយ បងប្អូនសាសនិកឥស្លាមកម្ពុជា រួចហើយសម្តេចក៏ នឹងមានគម្រោងជួបជាមួយបងប្អូនគ្រីស្តសាសនិកផងដែរ ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តថាទោះបីសម្តេចជាអ្នកកាន់ព្រះពុទ្ធសាសនា ក៏ប៉ុន្តែសុខដុមបនិយកម្មនយោបាយចំពោះសាសនាទាំងអស់មិនត្រូវរើសអើងទេ ដូច្នេះនៅពេលដែលខ្ញុំទៅស្រាយបួសជាមួយសាសនិកឥស្លាម ឬទៅជួបគ្រីស្តសាសនាសង្ឃឹមថា អ្នកកាន់ព្រះពុទ្ធសាសនាមិនធ្វើការតិះទានខ្ញុំក្នុងឋានៈសម្តេចជាអ្នកគ្រប់គ្រងទទួលខុសត្រូវដឹកនាំនយោបាយទូទៅទាំងក្នុង និងក្រៅប្រទេសនោះទេ។

## ពិភពលោកព្រួយបារម្ភ នឹងការផ្ទុះជំងឺគ្រុនលឿង

អ្នកជំនាញផ្នែកសុខាភិបាលនៅក្នុងប្រទេសមួយចំនួនកំពុងសំដែងការព្រួយបារម្ភអំពីការផ្ទុះឡើងនូវជំងឺគ្រុនលឿង។

ពួកគេបានព្រមានថា ការផ្ទុះករណីជំងឺគ្រុនលឿងនេះអាចក្លាយជាគ្រោះអាសន្នថ្មីរបស់សុខាភិបាលពិភពលោកខណៈកង្វះវ៉ាក់សាំងអាចបង្កឱ្យមានវិបត្តិ។ ជំងឺនេះត្រូវបានគេរាយការណ៍ថា មានការផ្ទុះទ្រង់ទ្រាយធំនៅប្រទេសអង់ហ្គោឡា អ៊ូ ហ្គង់ដា និងប្រទេសកុងហ្គោ។ ជំងឺគ្រុនលឿងនេះដែលចម្លងតាមរយៈមូសផ្ទុកមេរោគហ្ស៊ីកា។ គេដឹងថា គឺជាប្រភេទជំងឺដែលពិបាកនឹងចាប់រោគសញ្ញាបានណាស់ នៅដំណាក់កាលដំបូង ហើយវាក៏អាចឆ្លងរីករាលដាលយ៉ាងឆាប់រហ័សនៅទីប្រជុំជន។

អ្នកជំនាញអះអាងថា មូសប្រភេទនេះខាំមនុស្សនៅពេលថ្ងៃ និងរីដុះខ្លួនកាន់តែរឹងមាំអំឡុងអាកាសធាតុក្តៅបំផុត(អែល នីញ៉ូ ( El Nino ) )។

# ប្រជាពលរដ្ឋកម្ពុជាភាគច្រើនរង់ចាំចុះឈ្មោះបោះឆ្នោតរ

ពលរដ្ឋកម្ពុជាមួយភាគច្រើន គឺនៅតែមានចំណាប់អារម្មណ៍និងរង់ចាំធ្វើការចុះឈ្មោះបោះឆ្នោត សារជាថ្មី បើទោះបីជាពេលវេលានៃការចុះឈ្មោះបោះឆ្នោតត្រូវបានពន្យារពេលទៅដល់ពេលណាក៏ដោយ ដោយអះអាងថា នេះគឺជាកតាព្វកិច្ច ប៉ុន្តែខ្លះហាក់ស្ទាក់ស្ទើរ មិនចង់ចុះឈ្មោះ និងមិនចង់បោះឆ្នោត ដោយសារតែជិន-ណាយ នឹងសភាពការណ៍នយោបាយ ដែលមិនចេះត្រូវគ្នាសោះ។

លោក អ៊ុក ពិទូរ្យ ជាអាជីវករវ័យ ៤៥ ឆ្នាំ មួយរូប បានអះអាងថា ការចុះឈ្មោះបោះឆ្នោត និង ទៅបោះ ឆ្នោត គឺជាកាតព្វកិច្ច របស់យើងជាពលរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ។ ហើយលោកបានថ្លែងអះអាងថា ទោះបីជាដំណើរការចុះឈ្មោះបោះឆ្នោតនេះ ត្រូវពន្យារពេលដល់ណាក៏ដោយក៏លោក នឹងចូលរួមដែរ។

លោកបានបញ្ជាក់ថា " ប្អូន... ប្រាំឆ្នាំទៅតម្រង់ជួរ ចុះឈ្មោះម្តង វាមិនខាតពេលស្អីទេ។ ខ្ញុំនឹងទៅចុះនឹងគេ "។

លោកស្រី នាក់ ថានិត ជាស្ត្រីវ័យ ៤៨ឆ្នាំ មួយរូបបានអះអាងថា លោកស្រីបានធ្លាប់ចុះឈ្មោះបោះឆ្នោតនោះចំនួន ២ ដង រួចមកហើយ បើចុះថែមមួយទៀតក៏មិនអីដែរ ពីព្រោះនោះ គឺជាការសំដែងមតិសម្តែងឆន្ទៈ ហើយក៏ជាការចូលរួមចំណែកនៅក្នុងសង្គមប្រជាធិបតេយ្យនឹងគេផងដែរ ។

លោកស្រីបញ្ជាក់ថា "ការចុះឈ្មោះបោះឆ្នោតនេះសំខាន់ ដោយសារតែយើងមិនចុះទេ យើងមិនអាចទៅចូលរួមបោះឆ្នោតជ្រើសរើសមេដឹកនាំបានទេ"។

ក្រៅពីប្រជាពលរដ្ឋដែលកំពុងតែរង់ចាំចូលរួមដំណើរការបោះឆ្នោតនេះ ក៏មានប្រជាពលរដ្ឋមួយចំនួន ដូចជាមិនចង់រវីរវល់នឹងការចុះឈ្មោះ ឬចូលរួមការបោះឆ្នោតតទៅទៀត ។

បុរសដែលសុំបញ្ចេញតែអត្តសញ្ញាណថា ចំណានវ័យ ៣៩ឆ្នាំ បានឲ្យដឹងថា លោកបានចូលរួមចុះឈ្មោះបោះចំនួន ៣ ដង និងបោះឆ្នោតបាន ៥ដងនឹងគេដែរ ប៉ុន្តែក្រោយបោះឆ្នោត៥ អាណត្តិនេះ អ្វីៗគឺនៅតែដដែល ។

លោក ចំណាន បានអះអាងថា តាំងពីបោះឆ្នាំ ៩៣(១៩៩៣)មក យ៉ាងម៉េចមកដល់២០១៣ គឺនៅដដែល។ ក្រោយបោះឆ្នោត មិនដែលចេះត្រូវគ្នា ដល់ពេលមានការសម្របសម្រួល មានលាភសក្ការៈក៏ត្រូវ ល្អកល្អិននឹងគ្នា បានមួយរយៈ ក៏តាំងឈ្លោះគ្នាទៀតហើយ "។

លោកបានបញ្ជាក់ថា "សភាពការណ៍នយោបាយនៅកម្ពុជាតែតឹង។ មិនដែលថា បោះឆ្នោតហើយ ស្រុះស្រួលគ្នាធ្វើការជាមួយគ្នា ដល់ចប់អាណត្តទេ គឺឈ្លោះតែគ្នា ដណ្តើមតែអំណាច និងប្រជាប្រិយភាពហ្នឹង"។

នេះគឺជាទឹកចិត្តក៏ដូចជា យោបល់រួមចេញពីស្រទាប់មហាជន ដែលជាប្រជាពលរដ្ឋសាមញ្ញនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែសម្រាប់លោក គល់ បញ្ញា នាយកប្រតិបត្តិនៃគណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុម ហ្វ្រែល វិញដែលជាអង្គការសង្គមស៊ីវិលមួយ ដែលធ្វើការពាក់ព័ន្ធនឹងតាមដានដំណើរការរៀបចំការបោះឆ្នោតនៅកម្ពុជា ក៏បានចូលរួមបញ្ចេញយោបល់មួយចំនួនដែរ។

លោកបានមានប្រសាសន៍ថា យើងមានការព្រួយបារម្ភដែរអំពីសភាពការណ៍នយោបាយនៅក្នុងពេលបច្ចុប្បន្ននេះ បើទោះបីជា ការបោះឆ្នោតវានៅមានពេលរហូតដល់មួយឆ្នាំ។ នៅមុនពេលចុះឈ្មោះបោះឆ្នោតយើងឃើញថា សភាពការណ៍នយោបាយ គឺមានការភ័យខ្លាច។ ហើយការភ័យខ្លាចរបស់ប្រជាពលរដ្ឋនៅពេលបច្ចុប្បន្ននេះក៏អាចជះឥទ្ធិពលដល់ការបោះឆ្នោតនៅពេលខាងមុខដែរ។

លោកបានបញ្ជាក់ថា "នៅមុនការចុះឈ្មោះបោះឆ្នោតនេះ យើងគួរតែរក្សាសភាពការណ៍នយោបាយកុំឲ្យមានភាពភ័យខ្លាច ហើយកុំភ្លេចថា គាត់ចូលរួមនៅក្នុងការចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតក្តី គឺជាការសំដែងនូវឆន្ទៈដោយសេរីនៅក្នុងបរិយាកាសមួយ សន្តិភាពមិនមានការគំរាមកំហែង មុនការបោះឆ្នោត ក្នុងពេលបោះឆ្នោត និងក្រោយការបោះឆ្នោត ជារឿងធម្មតានៅក្នុងប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យ។ ការគំរាមកំហែងគឺអាចធ្វើឲ្យអ្នកបោះឆ្នោត គាត់ភ័យបាត់បង់នូវក្តីសង្ឃឹម និងប៉ះពាល់ដល់ឆន្ទៈគាត់។ ការប៉ះពាល់នេះ គឺអាចជាកត្តាបណ្តាលឲ្យគាត់មិនចង់ចូលរួមជាដើម នេះគឺជាការព្រួយបារម្ភរបស់យើង"។

បើតាម លោក គល់ បញ្ញា ស្ថានភាពដែលគួរឲ្យបារម្ភនៅកម្ពុជានៅពេលថ្មីៗនេះ គឺមានដូចជា ការឃាត់ខ្លួនសកម្មជនសិទ្ធិមនុស្ស ការចោទប្រកាន់និងការចាប់ខ្លួនអ្នកតំណាងរាស្ត្រគណបក្ស ប្រឆាំងជាដើម។

លោកបន្តទៀតថា ការចុះឈ្មោះបោះ-ឆ្នោតឆ្នាំនេះ គឺមានទំហំធំដោយយើងត្រូវ



ប្រជាពលរដ្ឋតម្រង់ជួរដើម្បីបោះឆ្នោត ២០១៣។ រូបភាពឯកសារ ដោយសម្បត្តិ

## "ធម្មតាការបញ្ចេញមតិ គឺមានការលើសល្អួសហើយ តែវាមិនមែនដូចជាបទឧក្រិដ្ឋ"

ចុះឈ្មោះឡើងវិញទាំងអស់។ ហើយចំនួនប្រជាពលរដ្ឋដែលត្រូវចុះឈ្មោះបោះឆ្នោតនោះក៏មានច្រើន គឺប្រមាណជា ១០លាននាក់ ដូច្នេះទំហំនៃកិច្ចការនោះ គឺធំដែលប្រជាពលរដ្ឋគាត់ត្រូវការមានបរិយាកាសនៃការចុះឈ្មោះបោះឆ្នោតដ៏ប្រសើរ ដើម្បីកុំឲ្យគាត់ភ័យខ្លាច ខណៈដែលបច្ចុប្បន្ននេះជាដំណាក់កាលមុនចុះឈ្មោះបោះឆ្នោត តែមានការប្រកួតប្រជែងនយោបាយ ការចោទប្រកាន់ ការចាប់ខ្លួនដាក់ពន្ធនាគារ។ល។ លោកបានបន្តទៀតថា ការអនុវត្តច្បាប់គឺជារឿងដែលសំខាន់ ហើយវាគឺជាផ្នែកមួយនៃការពង្រឹងនិតិរដ្ឋ ចង់ឲ្យមាននូវយុត្តិធម៌មួយ ខាងផ្នែកច្បាប់ផ្នែកសង្គមមួយបានល្អ ប៉ុន្តែយើងមើល ឃើញថាបរិយាកាសនៃការអនុវត្តច្បាប់នេះ គឺមួយចំនួនណានោះ គឺទាក់ទងនឹងការបញ្ចេញមតិ លើតំណាងរាស្ត្រគណបក្សប្រឆាំង និងលើសង្គមស៊ីវិល ដែលបានជួយលើកិច្ចការសិទ្ធិមនុស្សដោយចោទប្រកាន់តាមតុលា-ការ ហើយយកទៅដាក់ពន្ធនាគារ។ វាអត់សមស្របនឹងស្ថានភាពសង្គម ដោយសារតែសង្គមយើងនេះគេរកឃើញថា បទ-ឧក្រិដ្ឋនោះគឺមានច្រើនណាស់ និទណ្ឌ-ភាព ដែលជាឧក្រិដ្ឋកម្មធំក៏មានច្រើនដែរ ដែលគួរតែចាត់វិធានការទៅលើបញ្ហាហ្នឹងជាជាងយើងអនុវត្តលើអ្នកបញ្ចេញមតិ ទោះបីជាគេមានកំហុសបន្តិចបន្តួចក៏ដោយ គឺមិនគួរយកពួកគេទៅដាក់នៅពន្ធនាគារ ដូចជាឧក្រិដ្ឋកម្មធំៗទេ។

លោកបន្តទៀតថា ការអនុវត្តច្បាប់និងប្រព័ន្ធយុត្តិធម៌បែបហ្នឹងគឺមិនឆ្លើយតបនឹងអ្វីដែលគេហៅថា និតិរដ្ឋត្រឹមត្រូវនោះទេ ពីព្រោះថា គោលការណ៍គោរពសិទ្ធិមនុស្ស និងសិទ្ធិបញ្ចេញមតិហ្នឹងមិន

# តែខ្លះហាក់ជិនណាយនឹងសភាពការណ៍




អាចសុទ្ធតែជាកំហុស សុទ្ធតែជាបទល្មើស ហើយយកទៅដាក់នូវពន្ធនាគារនោះទេ។

លោកបានបញ្ជាក់ថា "ធម្មតាការបញ្ចេញមតិ គឺមានការលើសលួសហើយ តែវាមិនមែនដូចជាបទឧក្រិដ្ឋ ឧទាហរណ៍ ដូចជា អំពើពុករលួយ លួចថវិកាជាតិ កេងប្រវ័ញ្ចធនធានធម្មជាតិ របស់ជាតិ ឬក៏ឧក្រិដ្ឋកម្ម ភេរវកម្មធំៗ ដែលប៉ះពាល់ដល់សន្តិសុខជាតិ ការជួញដូគ្រឿងញៀននោះទេ"។

លោកបានបញ្ជាក់ទៀតថា "ស្ថានការណ៍បែបនេះគឺ មិនត្រឹមត្រូវទេ ស្ថានការណ៍បែបនេះ គឺអាចនាំដល់ការភ័យខ្លាចប៉ុន្តែបើអាជ្ញាធរបែរជាចាប់បានពួកឧក្រិដ្ឋកម្មធំៗបែបនោះជំនួសវិញ នោះប្រជាពលរដ្ឋគឺអាចដកការភ័យព្រួយវិញទេ ហើយមានអារម្មណ៍សន្តិសុខវិញ។

នៅជុំវិញការចុះឈ្មោះបោះឆ្នោតនេះ លោកបានបន្តទៀតថា យើងកំពុងតែដាក់ស្នើឲ្យគណៈកម្មការធិការជាតិរៀបចំការបោះឆ្នោតគួររៀបចំឲ្យហើយ។

លោកបានបន្តទៀតថា ប្រែកាសអំពីកាលបរិច្ឆេទនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឲ្យហើយ ដើម្បីសម្រួលដល់ការងារចុះឈ្មោះបោះឆ្នោត។ ពីព្រោះការចុះឈ្មោះបោះឆ្នោតនេះ គឺត្រូវបានកំណត់ថា យុវជនដែលមានអាយុគ្រប់ ១៨ ឆ្នាំត្រឹមថ្ងៃបោះឆ្នោត គឺអាចទៅចុះឈ្មោះបោះឆ្នោតបាន។

លោកបានបញ្ជាក់ថា "ការកំណត់កាលបរិច្ឆេទនេះ ក៏អាចជួយដែរដើម្បីកុំឲ្យដំណើរការចុះឈ្មោះនេះរំកិលទៅដល់ខែភ្លៀង។ ដោយសារតែការចុះឈ្មោះបោះឆ្នោតថ្មីនេះ គឺមានការប្រើប្រាស់កុំព្យូទ័រ ហើយក៏អាចរំខាន ដល់ការចុះឈ្មោះ ដូច្នេះបើបានមុនក៏ល្អ។

លោកបានអះអាងថា ការចុះឈ្មោះបោះឆ្នោតនៅក្នុងឆ្នាំ២០១៦ នេះ បើសិនជាអាចធ្វើបានគឺល្អ ដោយសារនៅសល់ពេល ត្រូវធ្វើបញ្ជីបោះឆ្នោតផ្លូវការ ហើយត្រៀមបោះឆ្នោត ២០១៨។ លោកបានបន្តថា បើការចុះឈ្មោះធ្វើបាននៅឆ្នាំនេះ ដំណើរការវារលូនបន្តិច។ បើបេះតែរំកិលពេលវេលា នៃការចុះឈ្មោះបោះ-ឆ្នោតទៀត គឺអាចមានបញ្ហាដោយសារតែការចុះឈ្មោះបោះឆ្នោតនេះវារាងយូរបន្តិចពោល គឺប្រហែលជា៣ខែអដែរ។

*ដោយ អរិយបុត្រ*

## គ.ជ.ប ពន្យាពេលការចុះឈ្មោះបោះឆ្នោតដល់ដើមខែ កញ្ញា

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសពីការពន្យារពេលនៃការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ សម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាតឆ្នាំ២០១៧ រហូតដល់ ដើមខែកញ្ញា ឆ្នាំ២០១៦ ដោយសារការផ្គត់ផ្គង់សម្ភារបច្ចេកទេសយឺត។

លោកហង្ស ពុទ្ធា ជាអ្នកនាំពាក្យនៃ គ.ជ.ប បានមានប្រសាសន៍ថា ការពន្យារពេលនេះ គឺដោយសារតែ គ.ជ.ប កំពុងតែរង់ចាំការមកដល់នៃកុំព្យូទ័រ ចំនួន ២.៤០០ គ្រឿង និងសម្ភារបច្ចេកទេសដែលឧបត្ថម្ភដោយសហភាពអឺរ៉ុបមានទឹកប្រាក់ប្រមាណជា ៥២ លានដុល្លារអាមេរិកមកដល់។

លោកបានបន្តថា បើទោះបីជា គ.ជ.ប ពន្យារពេលនៃការចាប់ផ្តើមដំណើរការចុះបញ្ជីបោះឆ្នោតមែន ប៉ុន្តែការពន្យារពេលនេះនឹងមិនប៉ះពាល់ដល់ ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់នាឆ្នាំ២០១៧ ខាងមុខឡើយ។

តាមការគ្រោងទុក គ.ជ.ប មានគម្រោងនឹងចាប់ផ្តើមដំណើការចុះបញ្ជីបោះ-ឆ្នោត នៅក្នុងខែនេះ ប៉ុន្តែដោយសារបញ្ហានេះក៏មានការពន្យាពេល ។

ចំនួនប្រជាពលរដ្ឋដែលគ្រប់អាយុ ត្រូវចុះឈ្មោះបោះឆ្នោតសរុបនៅកម្ពុជាសម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងការបោះឆ្នោតសាកលឆ្នាំ២០១៨ គឺមានចំនួនប្រមាណជា ១០ លាននាក់។

## រាជរដ្ឋាភិបាលកម្ពុជាប្រកាសកំណត់ការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់

កាលបរិច្ឆេទនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានកំណត់ធ្វើនៅថ្ងៃទី០៤ មិថុនា ២០១៧។ យោងទៅតាមសេចក្តីសម្រេចមួយ ដែលចុះហត្ថលេខាដោយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងទាំងអស់ជាពិសេស គឺទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចត្រូវគោរព។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍នៅក្នុងពិធីចែកសញ្ញាបត្រនិស្សិតសាកលវិទ្យាល័យអាស៊ីអឺរ៉ុបថា តាមពិតកាលបរិច្ឆេទ នៃការប្រកាសថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់ គឺត្រូវធ្វើ ៩ខែមុនពេលបោះឆ្នោត ប៉ុន្តែការប្រកាសនៅពេលនេះ គឺមុនប្រមាណមួយឆ្នាំ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការប្រកាសមុននេះ គឺដើម្បីឲ្យស្ថាប័នដែលពាក់ព័ន្ធត្រូវត្រៀមទុកជាមុន ក្រសួងស្ថាប័នរដ្ឋគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពលរដ្ឋទូទៅ គណបក្សនយោបាយទាំងអស់។ សម្តេចតេជោ ហ៊ុន សែន ក៏បានអំពាវនាវឲ្យប្រជាពលរដ្ឋកម្ពុជាដែលគ្រប់អាយុបោះឆ្នោតត្រូវទៅចុះឈ្មោះបោះឆ្នោត ដើម្បីទៅអនុវត្តសិទ្ធិខ្លួនឯង។

សម្តេចតេជោ ហ៊ុន សែន ក៏បានបង្ហាញនូវក្តីសង្ឃឹមថា ការបោះឆ្នោតលើកក្រោយនេះនឹងដំណើរការដោយរលូនហើយលែងមានការចោទប្រកាន់អំពីការបាត់ឈ្មោះបោះឆ្នោត ការលួចបន្លំសន្លឹកឆ្នោតដូចមុនទៀត ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កាលពីការបោះឆ្នោតមុនៗ គណបក្សប្រឆាំងទាមទារត្រឹមតែកំណែទម្រង់គណៈកម្មកាធិការជាតិរៀបចំការបោះឆ្នោតប៉ុណ្ណោះ ប៉ុន្តែសម្តេចបានស្នើឲ្យមានកំណែរ ទម្រង់ការបោះឆ្នោតទាំងមូលតែម្តងដោយរាប់ទាំងការចុះឈ្មោះតាមប្រព័ន្ធកុំព្យូទ័រឡើង ដើម្បីកុំឲ្យពេលប្រកាសលទ្ធផលចេះតែមានការតវ៉ា។ យោងទៅតាមសេចក្តីសម្រេចមួយ ដែលចុះហត្ថលេខាដោយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាក្រសួងទាំងអស់ជាពិសេស គឺទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច ត្រូវគោរព។

គណបក្សប្រជាជនកម្ពុជាបានទទួលជ័យជំនះភ្លូកទឹកភ្លូកដីដោយនៅក្នុងចំណោមអាសនៈជាសមាជិក ក្រុមប្រឹក្សាឃុំសង្កាត់ ចំនួន ១១.៤៥៩ កៅអីនៅក្នុងសង្កាត់ ឬឃុំ ១.៦៣៣ គឺគណបក្សប្រជាជនទទួលបាន ៨.២៩២ កៅអីដោយគ្រប់គ្រងឃុំ/សង្កាត់ សរុប១.៥៩២ ឬ ៩៧ភាគរយ នៃឃុំ/សង្កាត់នៅកម្ពុជា ។

# ព្រះវិហារគ្រួសារដ៏វិសុទ្ធ(អ្នកលឿង)បើកសិក្ខាសាលាយុវជនរយៈពេល៣ថ្ងៃ




ព្រះវិហារគ្រួសារដ៏វិសុទ្ធ(អ្នកលឿង) បើកសិក្ខាសាលាយុវជនរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី១៣-១៥ ឧសភា ២០១៦កន្លងទៅក្រោមប្រធានបទ ៖ ឆ្នាំមហាករុណាទិគុណ មានយុវជន ១០០នាក់ចូលរួម។

ឆ្នាំមេត្តាករុណា គឺជាជីវិតរបស់ព្រះជាម្ចាស់មិនមែនមានតែមួយឆ្នាំតែប៉ុណ្ណឹង គឺមានជីវិតអស់កល្បជានិច្ច។

បងប្រុស សែ សាត ជាអ្នករៀបចំសិក្ខាសាលាបានមានប្រសាសន៍ថា៖ ក្នុងប្រធានបទនេះ គឺធ្វើយ៉ាងណាឲ្យយុវជនធ្វើអ្វីមួយពិសេសសម្រាប់ខ្លួនឯង និងសម្រាប់ព្រះសហគមន៍ និងអស់បងប្អូន ហើយជាឆ្នាំដែលយើងម្នាក់ៗទទួលព្រះពរ និងការលើកលែងទោសយ៉ាងពិសេសពីព្រះជាម្ចាស់។

នៅតាមថ្ងៃនីមួយៗពួកគេមានប្រធានបទមួយសំរាប់អនុវត្តន៍ នៅថ្ងៃទី១ ឲ្យគេស្គាល់ ថ្ងៃទី២ កិច្ចការនៃឆ្នាំមហាករុណាទិគុណ និងថ្ងៃទី៣ឲ្យគេសំរេចចិត្ត។

មានសកម្មភាព១៤ ក្នុងឆ្នាំនេះ តើពួកគេអាចធ្វើអ្វីបាន? ឲ្យយុវជនទទួលស្គាល់ថា ព្រះមហាករុណាទិគុណរបស់ព្រះជាម្ចាស់មានគ្រប់ពេលវេលា មិនមែនតែមួយឆ្នាំ ឬមួយពេលនោះឡើយចំពោះគេ ហើយគេទទួលថានោះជាជីវិត របស់ពួកគេ។

នៅថ្ងៃទី១៖ ឲ្យពួកគេស្គាល់ និងគិតពីឡូហ្គោ (មើលទៅដូចមនុស្ស ២នាក់ ភ្នែក ៣ រង្វង់ពណ៌ផ្សេងៗ រូបព្រះយ៉េស៊ូមានរបួស) និងពាក្យស្លោក(ចូរមានចិត្តមេត្តាករុណាដូចព្រះបិតា) យើងនឹងពន្យល់គេថាទាំងអស់នោះមានន័យថា ៖ ព្រះជាម្ចាស់មានព្រះហឫទ័យ ប្រណីសន្តោស លើកលែងទោស និងសង្គ្រោះយើង ក្រោយមកទើបបានជាពាក្យស្លោក ចូរមានចិត្តមេត្តាករុណាដូចព្រះបិតាដើម្បីឲ្យពួកគេចងចាំ និងយកគំរូតាមក្នុងជីវិត។ ក្នុងនោះមានសំដែងរឿងអ្នកស្រុកសាម៉ារី មានចិត្តសប្បុរស ត្រង់ចំណុចនរណាជាបងប្អូនខ្ញុំ? លោកបានពន្យល់និងប្រៀបធៀបថាព្រះយេស៊ូលាបរបួសឲ្យអ្នកជំងឺ ការពិតព្រះបិតាផ្ទាល់ ដែលលាបរបួសឲ្យយើងម្នាក់ៗ ពេលយើងមានជំងឺ ហើយព្រះយេស៊ូតែងត្រាស់ហៅយើងឲ្យទៅធ្វើដូចអ្នកស្រុកសាម៉ារីនោះ។

ឆ្នាំព្រះមហាករុណាទិគុណ ឆ្នាំលើវិន័យគឺឆ្នាំនៃការលើកលែងទោស ឬឆ្នាំសម្បត្តិដែលរៀងរាល់៥០ឆ្នាំម្តង ព្រះជាម្ចាស់សុំឲ្យជនជាតិអ៊ីស្រាអែលឈប់ធ្វើស្រែចំការលើដី ដោះលែងទោសទាសករពីផ្ទះឲ្យមានសេរីភាពឡើងវិញ ទាំងនេះជាប្រភពនៃឆ្នាំមហាករុណាទិគុណកើតឡើង។ អត្ថន័យទ្វារដ៏វិសុទ្ធរបស់ព្រះសហគមន៍កាលពីមុនព្រះសហគមន៍មានទ្វារដ៏វិសុទ្ធតែមួយគត់ គឺនៅទីក្រុងរ៉ូម ដូច្នេះបើចង់ឆ្លងទ្វារដ៏វិសុទ្ធដើម្បីជួបព្រះហឫទ័យ និងទទួលការលើកលែងទោសព្រះជាម្ចាស់ នោះលុះត្រាតែបូជនីយចរទៅកាន់ក្រុងរ៉ូម។ តែឆ្នាំនេះជាឆ្នាំដ៏ពិសេសដែលសម្តេចប៉ាបអនុញ្ញាតិឲ្យមានទ្វារដ៏វិសុទ្ធនៅតាមភូមិភាគរបស់ខ្លួន គ្រីស្តបរិស័ទអាចបូជនីយចរទៅកាន់ភូមិភាគរបស់ខ្លួនដែលមានទ្វារដ៏វិសុទ្ធ ដើម្បីជួបព្រះហឫទ័យ និងទទួលបានការលើកលែងទោសព្រះជាម្ចាស់។ បងប្រុស សាត បន្តថា ឲ្យពួកគេរិះគិតសកម្មភាពទាំង១៤ ដែលមាន៧ខាងផ្លូវកាយ និង៧ខាងផ្លូវវិញ្ញាណ។

ផ្លូវកាយ៖ ឲ្យទឹក អាហារ ជំរកសំលៀកបំពាក់ ទទួលជនបរទេស។ល។ ផ្លូវវិញ្ញាណ៖ ការលួងលោម លើកលែងទោស ការអធិដ្ឋាន។ល។ ឲ្យក្រុមនីមួយៗគិតហើយសំដែងជា សាច់រឿង ក្រោយមក ឲ្យពួកគេចុះទៅផ្ទាល់តាមផ្ទះអ្នកជំងឺ ឬមន្ទីរពេទ្យទៅតាមអ្វីដែលពួកគេអាចធ្វើបាន (បោសជូត ចែកអាហារ ចំអិនអាហារ បោកសំលៀកបំពាក់ )។ល។

នៅថ្ងៃបញ្ចប់ នោះឲ្យពួកគេសំរេចចិត្តថា កិច្ចការទាំង១៤នេះ ពួកគេអាចធ្វើអ្វីបានខ្លះ? ដូច្នេះម្នាក់ៗ រិះគិតនិងបំពេញកិច្ចការនេះជាប្រចាំ។

លោកសង្កេតឃើញថា លទ្ធផលដែលពួកគេទទួលបានច្រើនដែល ធ្វើឲ្យពួកគេយល់ថា ឆ្នាំមហាករុណាទិគុណជាឆ្នាំនៃការលើកលែងទោសព្រះជាម្ចាស់មានព្រះហឫទ័យ ស្រលាញ់ខ្លាំងលើសអ្វីៗទាំងអស់ ហើយព្រមលើកទោសឲ្យយើងគ្រប់យ៉ាង។

បងប្រុសបានផ្តាំផ្ញើទៅកាន់យុវជនថា ព្រះជាម្ចាស់ស្រលាញ់យើងម្នាក់ៗឥតព្រំដែន ទោះបីយើងជាមនុស្សបែបណាក៏ដោយ ហើយព្រះអង្គរង់ចាំជានិច្ចដើម្បីសង្គ្រោះយើង។ សូមឲ្យពាក្យដែលមាននៅក្នុងចិត្តយើងម្នាក់ៗនោះគឺ ៖ ចូរមានចិត្តមេត្តាករុណាដូចព្រះបិតាជាពាក្យដែលស្រួលនិយាយ ហើយព្យាយាមធ្វើ។ បើយុវជនិយាយច្រើនដងពាក្យនោះ និងចូលក្នុងបេះដូងរបស់យុវជន ហើយនិងក្លាយជាជីវិតរបស់យើងម្នាក់ៗ។ *ស្រីម៉ាច*

---

# ទិវាកុមារអន្តរជាតិនៅព្រះសហគមន៍កោះរកា

"កុមារដឹងគុណមាតាបិតា" ជាប្រធានបទនៅក្នុងកម្មវិធីទិវាកុមារអន្តរជាតិនៃព្រះសហគមន៍កាតូលិក កោះរកា ស្ថិតក្នុងភូមិភាគកំពង់ចាម កាលពីថ្ងៃពីទី២៩ ឧសភាកន្លងទៅ។

កញ្ញា ស្រីឡៃ ផ្នែកយុវជននិងជាអ្នករៀបចំកម្មវិធីទាំងមូលបានឲ្យដឹងថា ៖ ព្រះសហគមន៍តែងតែរៀបចំកម្មវិធីទិវាកុមារអន្តរជាតិនេះជារៀងរាល់ឆ្នាំដោយពេលខ្លះធ្វើនៅក្នុងព្រះសហគមន៍ និងពេលខ្លះក៏ចេញទៅប្រារព្ធនៅតាមសាលាបឋមសិក្សាខាងក្រៅដែលស្ថិតនៅក្នុងភូមិកោះរកា។ នាងបន្តថា៖ ក្នុងឆ្នាំនេះខាងព្រះសហគមន៍បានរៀបចំកម្មវិធីជាច្រើនសប្បាយ និងការអប់រំដល់កុមារមួយចំនួនដូចជា៖ សម្តែងរឿងអប់រំខ្លី សម្តែងរបាំចម្រៀងកាយវិការ និងការលេងល្បែងរួមគ្នាយ៉ាងសប្បាយរីករាយ។

កុមារប្រមាណជា២៥០ រួមជាមួយអាណាព្យាបាល១០០នាក់ ក៏មានការចូលរួមចំណែកពីលោកមេភូមិ មេឃុំ នៅតំបន់កោះរកាផងដែរ។

កញ្ញាស្រី ឡៃ បានឲ្យដឹងអំពីគោល-បំណងក្នុងពិធីទិវាកុមារអន្តរជាតិនេះថា ៖ កម្មវិធីនេះធ្វើឡើងដើម្បីលើកទឹកចិត្តដល់កុមារទាំងអស់ឲ្យមានទំនុកចិត្តសេចក្តីក្លាហាន និងស្គាល់ពីសិទ្ធិ និងតួនាទីរបស់ខ្លួនក្នុងសង្គម។ ម្យ៉ាងវិញទៀតក៏ជាពេលវេលាមួយដើម្បីឲ្យអាណាព្យាបាលទាំងអស់យកចិត្តទុកដាក់ថែរក្សាកុមារជំរុញ និងបញ្ជូនកុមារឲ្យទទួលបានការសិក្សាអប់រំមិនបំពានកំលាំងពលកម្មរបស់កុមារជាពិសេសលុបបំបាត់ការប្រើអំពើហិង្សាទៅលើកុមារតែម្តង។

ព្រះសហគមន៍កាតូលិកកោះរកាតែងតែយកចិត្តទុកដាក់ទៅលើកុមារ និងយុវជនដូចជា ជួយបង្រៀនផ្នែករបាំ បង្រៀនភាសាអង់គ្លេស ភាសាខ្មែរ និងបង្រៀនអំពីអនាម័យផងដែរ។



កញ្ញាស្រីឡៃ បានបន្ថែមឲ្យដឹងទៀតថា ៖ កម្មវិធីទិវាកុមារអន្តរជាតិនេះមានរយៈពេលខ្លីមែនតែអ្វីដែលសំខាន់នោះគឺវាមានអត្ថន័យសម្រាប់កុមារព្រោះធ្វើឲ្យពួកគេមានភាពក្លាហានជាងមុនហ៊ានបង្ហាញពីអាម្មរណ៍ពិតចំពោះ អាណា-ព្យាបាល បង្ហាញនូវទេពកោសល្យ និងបញ្ចេញនូវស្នាមញញឹម និងយល់កាន់តែច្បាស់អំពីសិទ្ធិរបស់ពួកគេតែម្តង។

*រឿន ស្រីម៉ាច*

# កុមារជនបទទទួលបានការអប់រំតាមគរុកោសល្យម៉ុងតេសូរី



អគារមត្តេយ្យសិក្សាចំនួន៤ខ្នង បានបើសម្ពោធជាផ្លូវការដាក់ឲ្យប្រើប្រាស់ក្រោមអធិបតីភាពរបស់លោកជំទាវ យុន រចនា អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា រួមជាមួយលោកអូលីវីយេ ដ្មឹត អឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ កាលពីថ្ងៃទី១៦ ឧសភា ២០១៦ នៅភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។ មត្តេយ្យសិក្សានេះឈ្មោះថា សន្តិថេរេសានៃព្រះកុមារយេស៊ូ។

តាមប្រសាសន៍របស់លោកអភិបាល អូលីវីយេ បានឲ្យដឹងថា៖ មត្តេយ្យសិក្សានេះ ការបង្រៀនគឺអនុវត្តន៍តាម គរុកោ-សល្យម៉ុងតេសូរី ដែលជាគរុណកោសល្យមួយ បង្កើតឡើងក្នុងសតវត្សទី១៩ ដោយលោកស្រី ម៉ារីយ៉ា ម៉ុងតេសូរី ជាជនជាតិអ៊ីតាលី។ គរុកោសល្យនេះ គឺជាការភ្ជាប់រវាងកុមារតូច និងមនុស្សធំក្នុងមួយថ្ងៃៗ កុមាររើសអ្វីដែលគេចង់រៀនដូចជាអក្សរ លេខ ធ្វើម្ហូប លេងល្បែងផ្សេងៗ។ល។ គ្រូត្រូវរៀបចំគ្រប់ឧបករណ៍ឲ្យកុមារដើម្បីជួយឲ្យកុមារតូច មានម្ចាស់ការ ឯករាជ្យ ក្លាហាន បញ្ចេញអស់សមត្ថភាព និងអស់ពីកម្លាំងកាយរបស់គេ។

កម្មវិធីគរុកោសល្យនេះរីកចម្រើនខ្លាំងនៅសហរដ្ឋអាមេរិក អាស៊ី មានជប៉ុនជាដើម។ មត្តេយ្យ មានមិនច្រើនទេនៅកម្ពុជាដែលមានការអនុវត្តគរុកោសល្យនេះហើយចូលរៀនត្រូវបង់ថ្លៃណាស់។ ចំពោះនៅទីនេះ គឺបង់អង្ករ១គីឡូក្រាមប៉ុណ្ណោះក្នុងមួយខែ។

លោកអភិបាលក៏បានលើកឡើងអំពីសមាគមសិក្សាលោកថា ៖ ត្រូវមានការចូលរួមទាំងអស់គ្នា មាតាបិតា អ្នកភូមិសិស្ស គ្រូទាំងអស់គ្នា រួមគ្នាដើម្បីជួយឲ្យកុមាររីកចម្រើនឡើង ជួយរៀបចំអនាគតរបស់កុមារពិតៗ។ គ្រូយកចិត្តទុកដាក់បង្រៀន មាតាបិតាត្រូវយកចិត្តទុកដាក់តាមដានការសិក្សារបស់កូន។

លោកក៏មានប្រសាសន៍ដែរថា៖ ការសិក្សាជាអាទិភាពមួយ របស់ព្រះសហ-គមន៍កាតូលិក។ ដូចបងប្អូនបានឃើញសមិទ្ធផលនៅទីនេះស្រាប់។ លោកមានសុទិដ្ឋិនិយមថា គ្រប់កម្មវិធីសិក្សាដែលមាននៅទីនេះនឹងឲ្យកុមារស្រឡាញ់ការសិក្សា លោកជឿជាក់ថា សាលាមត្តេយ្យជាអនាគតសម្រាប់រៀបចំប្រទេសកម្ពុជាឲ្យរីកចម្រើនថែមទៀត។

អាគារសិក្សាថ្មីដែលបានដាក់សម្ពោធនៅថ្ងៃនេះ គឺសុទ្ធតែមានបំពាក់ដោយឧបករណ៍គ្រប់គ្រាន់សម្រាប់កុមារសិក្សាមានផ្ទាំង អក្សរ លេខ ក្តារបន្ទះសម្រាប់រៀបរូប និងមានសម្ភារជាច្រើនទៀត។ បន្ទប់ធំទូលាយ មានអាគារបណ្ណាល័យដាច់ដោយឡែកសម្រាប់កុមារអានសៀវ-ភៅ អគារសម្រាប់កុមារបញ្ចេញទេព-កោសល្យសិល្បៈ មានបំពាក់ឧករណ៍នៅទីធ្លា សម្រាប់កុមារកំសាន្ត បន្ទប់ទឹកស្រីប្រុស បន្ទប់សម្រាប់កុមារកេងពេលថ្ងៃ។

ការបង្រៀនពិតណាស់ត្រូវតែយកចិត្តទុកដាក់ និងត្រូវមានសម្ភារគ្រប់គ្រាន់ អ្នកគ្រូស៊ុវ៉ាន់ណៃ បានរៀបរាប់ថា ដោយមានការជួយអប់រំជំរុញ ពីដូនជីកាតូលិកពីប្រទេសជប៉ុន គឺឲ្យអ្នកគ្រូអាចបង្រៀនតាមគរុកោសល្យ ម៉ុតេសូរីនេះបាន ហើយឃើញថា កុមារមានភាពរីកចម្រើនលឿន និងមានភាពក្លាហាន។ ស៊ុវ៉ាន់ ណៃក៏បានលើកឡើងនូវឧបសគ្គមួយចំនួនដែលបានជួបគឺ គ្រូទាំងអស់ត្រូវតែចេះផលិតសម្ភារសម្រាប់បង្រៀន សម្រាប់សិស្សសិក្សាត្រូវមានគំនិតថ្មីជានិច្ចដែរ។

ក្នុងពិធីដ៏ប្រសើរនេះលោកជំនាវ យុន រចនា អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា បានមានប្រសាសន៍អប់អរសាទរ និងថ្លែងអំណរគុណចំពោះលោកអភិបាល អូលីវីយេ ដែលបានយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត បណ្តុះបណ្តាលធនធានមនុស្សសម្រាប់ប្រទេសកម្ពុជា។ លោកជំនាវក៏ត្រេកអរដែលកម្មវិធីសិក្សាតាមបែបម៉ុងតេសូរីនេះត្រូវបានអនុវត្តន៍នៅសាលាមត្តេយ្យនេះ។ នៅក្នុងសារផ្ញើជូនលោកអភិបាល អូលីវីយេ លោកជំនាវបានសរសើរ មត្តេយ្យសាលានេះពិតជាល្អណាស់ និងជាគំរូសម្រាប់សាលាឯទៀតៗនៅកម្ពុជា។ លោកជំទាវអគុណលោកអភិបាល ដោយបានដាក់នាមថា ៖ "លោកអភិបាលជា វិរបុសនៃការអប់រំក្នុងប្រទេសកម្ពុជា"។

ក្នុងពិធីដ៏ឱឡារិកនេះលោកស្រីបន្តថា កសាងធនធានមនុស្សពិតជាមិនអាចខ្វះបាន ព្រោះការអភិវឌ្ឍប្រទេសត្រូវការណាស់ធន់ធានមនុស្ស។ ការអប់រំកុមារតូចជាអនុវិស័យមួយដែលក្រសួងអប់រំបានយកចិត្តទុកដាក់។

នៅក្នុងឱកាសនេះលោកជំនាវក៏បានអំពាវនាវឲ្យមាតាបិតា យល់អំពីការអប់រំកុមារតូច ព្រោះសំខាន់ណាស់ ជាពេលវេលាដែលកុមាររីកចម្រើន។ អំពាវនាវឲ្យមានការចូលរួមគ្រប់វិស័យទាំងអស់ឯកជន សហគមន៍ និងក្រសួង។ ត្រូវចូលរួមទាំងអស់គ្នាដើម្បីអប់រំ។ សូមថែរក្សាសមិទ្ធិផលដែលមាននៅទីនេះ។

តាមរយៈរបាយការណ៍របស់នាយិការការិយាល័យអប់រំភូមិភាគភ្នំពេញលោកស្រី ឡៃ មករា បានឲ្យដឹងថា ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានមត្តេយ្យសិក្សាចំនួន ២៥កន្លែងក្នុងប្រាំតំបន់ផ្សេងគ្នា គឺខេត្តព្រះសីហនុ ចំនួន ៤កន្លែង ភ្នំពេញមាន ៣កន្លែង អង្គការយូហ្វេរ ចំនួន ៣កន្លែង តំបន់ទន្លេមេគង្គ និងទន្លេបាសាក់ចំនួន ៦កន្លែង និងតំបន់កំពត់ និងតាកែវមានចំនួន ៩កន្លែង។ នៅក្នុងនោះមាន ២កន្លែង ដែលអនុវត្តន៍តាមគរុកោសល្យម៉ុងតេសូរី គឺកំពតនិងមត្តេយ្យសាលសន្តី ថេរេសា នៃព្រះកុមារយេស៊ូចំការទៀង។ សាលាមត្តេយ្យសន្តីថេរេសា កសាងក្នុងឆ្នាំ២០០២ ឆ្នាំសិក្សា ២០១៥ -២០១៦ មានសិស្សចំនួន ៤០ នាក់ មានបុគ្គលិក ១១នាក់ ក្នុងនោះគ្រូ ៥ នាក់។

*ដោយលោក លី សុវណ្ណា*

# មរតករបស់គ្រីស្តបរិស័ទ គឺចិត្តមេត្តាករុណា




គ្រីស្តបរិស័ទជាច្រើនសាសន៍សរុបជាង១០០០នាក់បានចូលរួមជាមួយគ្នាដើម្បីចូលរួមប្រារព្ធពិធីបុណ្យព្រះវិញ្ញាណយាងមក ក្រោមអធិបតីភាពរបស់លោកអភិបាលអូលីវីយេ ឆ្មីតអីស្លែរ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលបានធ្វើឡើងកាលពីថ្ងៃទី១៥ ឧសភាកន្លងទៅ នៅព្រះវិហារសន្តយ៉ូសែប នៃព្រះសហគមន៍ផ្សារតូចនារាជធានីភ្នំពេញ។

ថ្លែងនៅក្នុងអង្គពិធីបុណ្យ លោកអភិបាលអូលីវីយេមានប្រសាសន៍ថា មរករបស់ព្រះបិតាដែលមានសម្រាប់យើងគឺ "ចូរមានចិត្តមេត្តាករុណា" ដែលនាំឲ្យយើងដូចព្រះបិតាដែលមានចិត្តមេត្តាករុណានិងស្រឡាញ់។ លោកអភិបាលបន្ថែមថា"គឺព្រះវិញ្ញាណផ្ទាល់ដែលផ្តល់សក្ខីភាពឲ្យវិញ្ញាណយើងអាចនិយាយថា យើងពិតជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងនឹងទទួលមរកពីព្រះជាម្ចាស់"។

បុណ្យព្រះវិញ្ញាណយាងត្រូវបានប្រារព្ធធ្វើជារៀងរាល់ឆ្នាំ គឺនៅ៥០ថ្ងៃក្រោយបុណ្យព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង។ ពិធីបុណ្យនេះធ្វើឡើងដើម្បី រំលឹកដល់ថ្ងៃព្រះជាម្ចាស់ចាត់ព្រះវិញ្ញាណរបស់ព្រះអង្គឲ្យមកគង់សណ្ឋិតលើក្រុមគ្រីស្តទូតដើម្បីទៅប្រកាសដំណឹងល្អអំពីនៃការសង្គ្រោះរបស់ព្រះជាម្ចាស់។

លោកអភិបាលអូលីវីយេ បន្តថា នៅថ្ងៃនេះ ជាពេលវេលាដែលយើងត្រូវទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកជាថ្ងៃដែលព្រះសហគមន៍ទទួលបេសកកម្មពីព្រះយេស៊ូ គឺណែនាំឲ្យមនុស្សកែប្រែចិត្តគំនិត ឲ្យគេជ្រមុជទឹក និងទៅប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ឲ្យដល់ទីដាច់ស្រយាលនៃផែនដី។ លោកអភិបាលបានបញ្ជាក់ថា កិច្ចការប្រកាសដំណឹងល្អ គឺជាកិច្ចការធម៌មេត្តាករុណា។ "យើងដឹងហើយថា សម្រាប់យើងដែលជាគ្រីស្តបរិស័ទកិច្ចការមេត្តាករុណានេះមានសារៈសំខាន់បំផុតនិងជាចំណុចកំពូល ដូចសម្តេចប៉ាបបេណេឌិកតូទី១៦បាននិយាយ ចូរឲ្យយើងប្រកាសដំណឹងល្អជាពិសេសចំពោះអ្នកតូចតាច"។

កិច្ចការធម៌មេត្តាករុណាចែកចេញជា២គឺខាងផ្លូវកាយមានចំនួន៧ ដែលមានដូចជា ការចែកម្ហូបអាហារ ចែកទឹក ចែកសំលៀកបំពាក់ ទទួលជនភៀសខ្លួន សួរសុខទុក្ខអ្នកជំងឺ លើកទឹកចិត្តអ្នកជាប់ឃុំឃាំង និងបញ្ចុះសព។ មេត្តាករុណាផ្លូវវិញ្ញាណមាន៧គឺ ឲ្យដំបូន្មានអ្នកឆ្ងល់អំពីជំនឿ បង្រៀនមនុស្សដែលមិនស្គាល់មិនទទួលព្រះយេស៊ូ ដាស់តឿនអ្នកធ្វើខុស មានចិត្តអំណត់ចំពោះអ្នកធ្វើខុសមកលើខ្លួន លើកលែងទោសដល់អ្នកធ្វើខុសចំពោះយើង លើកទឹកចិត្តអ្នកមានទុក្ខនិងអស់សង្ឃឹម និងអធិដ្ឋានសម្រាប់អ្នកនៅរស់ និងស្លាប់។

លោកអភិបាលក៏បានជំរុញបន្ថែមឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់អំពី យុត្តិធម៌សង្គម និងសិទ្ធិមនុស្ស និងឲ្យគ្រីស្តបរិស័ទទៅជាដែលអ្នកសាបព្រោះយុត្តិធម៌ ដែលជាតួនាទីមួយរបស់គ្រីស្តបរិស័ទនៅក្នុងការចូលរួមកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ លោកអភិបាលអូលីវីយេ "យើងត្រូវការចង់ចាំអំពីព្រះបន្ទូលរបស់ព្រះយេស៊ូដែលថា អ្នកណាស្រេកឃ្លានយុត្តិធម៌អ្នកនោះមានសុភមង្គលហើយ អ្នកណាកសាងសុខសន្តិភាពអ្នកនោះមានសុភមង្គលហើយ។ នេះជាតួនាទីរបស់យើងបានទទួល ហើយខ្ញុំជឿថា សម្រាប់យើងជាគ្រីស្តបរិស័ទពីមួយថ្ងៃទៅមួយថ្ងៃ នៅពេលយើងស្តាប់ព័ត៌មានក្នុងវិទ្យុនៅក្នុងប្រទេស ក៏ដូចជាព័ត៌មាននៅក្នុងពិភពលោកទាំងមូល ជំរុញឲ្យដួងចិត្តរបស់យើងស្រែក ឱសេចក្តីសុខសូមយាងមកដើម្បីបំភ្លឺពិភពលោក ឱសេចក្តីសុខសូមយាងមកកុំឲ្យយើងបន្តមានសង្គ្រាម ការមើលងាយ ការបាក់បែកគ្នា អំពើអយុត្តិធម៌ដែលណែនាំឲ្យយើងរស់នៅក្នុងភាពងងឹត។

ក្នុងនោះដែរលោកអភិបាលបានរំលឹកឲ្យគ្រីស្តបរិស័ទចាប់អារម្មណ៍បន្ថែមលើចំណុចអាទិភាព៧វិស័យនៅក្នុងឆ្នាំមហាករុណាទិគុណប្រណីសន្តោសរបស់ព្រះជាម្ចាស់ គឺអំពីការសិក្សា សុខភាព អ្នកក្រីក្រពលករ ការថែរក្សាធម្មជាតិ សន្ទនាអន្តរសាសនា និងជនពិការ។ លោកអភិបាលក៏បានលើកទឹកចិត្តដល់គ្រីស្តបរិស័ទតាមព្រះសហគមន៍នីមួយៗឲ្យយកពេលវេលាដើម្បីធ្វើបូជនិយចរិះគិតអំពី ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ផងដែរ។ "ខ្ញុំជឿថា នៅពេលព្រះសហគមន៍នីមួយៗធ្វើបូជនិយចរទៅកាន់ភ្នំពេញថ្មី ផ្សារតូច និងអរិយក្សត្រ ដែលទទួលព្រះកាយព្រះគ្រីស្ត ទទួលអគ្គសញ្ញាលើកលែងទោស ជាឱកាសមួយដើម្បីឲ្យមានបទពិសោធន៍ជាក់ស្តែង ពិតមែនព្រះបិតាស្រឡាញ់ខ្ញុំ ហើយពេលខ្ញុំទទួលសេចក្តីស្រឡាញ់នេះ ខ្ញុំចែកជាមួយគេបាន"។

លោកអភិបាលក៏បានរំលឹកទៀតថា ក្នុងនាមជាគ្រីស្តបរិស័ទ ឲ្យយើងចេះបង្ហាញភាពជាធ្លុងតែមួយទៅដល់សង្គមជាតិ ទោះសញ្ជាតិផ្សេងគ្នា និយាយភាសាផ្សេងគ្នាក៏ដោយ ដូចព្រះយេស៊ូជាធ្លុងតែមួយជាមួយព្រះបិតា។ លោកអភិបាល "ឲ្យយើងយល់ថា ពិតមែនយើងជាគ្រួសារតែមួយ ហើយនេះជាតួនាទីរបស់យើង ដើម្បីឲ្យយើងមានចិត្តគំនិតតែមួយចិត្តថ្លើមតែមួយរួមជាមួយមិត្តសម្លាញ់ ក្រុមគ្រួសារ ជាមួយបងប្អូន ជាមួយបូជាចារ្យ លោកអភិបាល ជាមួយសម្តេចប៉ាប នៅកន្លែងដែលយើងធ្វើការ នៅក្នុងសង្គម នៅក្នុងអាស៊ានរបស់យើងឲ្យយើងទៅជាអង្គតែមួយ ដើម្បីបំពេញតួនាទីដែលយើងបានទទួលពីព្រះយេស៊ូ គឺកសាងពិភពលោកថ្មីដែលចេះសហការគ្នា ចេះស្រឡាញ់គ្នា ចេះរៀបក្រុមគ្រួសារតែមួយ ដោយសារយើងមានព្រះបិតាតែមួយដែលស្រឡាញ់យើងទាំងអស់ នេះជាផលនៃព្រះវិញ្ញាណដ៏វិសុទ្ធ"។ *កញ្ញា*

# ព្រះសហគមន៍ប្រារព្ធ ទិវាមហាករុណាទិគុណសម្រាប់អ្នកជំងឺនិងជនពិការ



ព្រះវិហារសន្តប៉ូល និងសន្តសិលា បានរៀបចំកម្មវិធីទិវាមហាករុណាទិគុណសម្រាប់អ្នកជំងឺនិងជនពិការ កាលពីថ្ងៃទី១២ មិថុនាកន្លងទៅ សម្រាប់អស់អ្នកជំងឺ និងជនពិការប្រមាណ៥០គ្រួសារ នៅក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ នៅថ្ងៃទី១២ មិថុនានេះ សម្តេចប៉ាបហ្វ្រង់ស៊ីស្គ បានស្នើសុំឲ្យព្រះសហគមន៍នីមួយៗយកចិត្តទុកដាក់ជាពិសេសដល់អ្នកជំងឺ និងជនពិការ។ ស្របតាមការស្នើសុំនេះ លោកអភិបាលអូលីវីយេ ឆ្មឹតអឺស្លែរ នៃព្រះសហគមន៍ភូមិភាគភាគភ្នំពេញបានជំរុញឲ្យមានទិវាមហាករុណាទិគុណនេះឡើងរយៈពលេពីរថ្ងៃគឺពីថ្ងៃទី១១ ដល់ទី១២ មិថុនាតាមមណ្ឌលសកម្មភាពនៃព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញ។

លោកអភិបាលបានមានប្រសាសន៍កាលពីថ្ងៃទី១២ មិថុនានៅព្រះវិហារសន្តប៉ូលនិងសន្តសិលាថា "សម្រាប់ភូមិភាគភ្នំពេញ យើងមាន២ថ្ងៃ ណែនាំឲ្យយើងជាពិសេសបងប្អូនគ្រីស្តបរិស័ទ ទៅសួរសុខទុក្ខតាមកន្លែងដែលយើងមានអ្នកជំងឺ និងអ្នកពិការ និងជាឱកាសមួយដើម្បីបង្កើតសកម្មភាពផ្សេង ក្រៅពីអធិដ្ឋាន គឺទៅសួរសុខទុក្ខផងនិងចែកអំណោយ ឬជប់លៀងជុំគ្នា និងជាពិសេសលើកទឹកចិត្តនិងសម្តែងមេត្តាករុណារវាងគ្នា"។

លោកមាន ចាន់ ជាមនុស្សពិការជើងមួយចំហៀងអស់រយៈពេលបួនឆ្នាំមក ហើយដោយសារឈឺគ្មានប្រាក់ព្យាបាល។ គាត់មកពីភូមិឫស្សី ក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញបានមកទទួលអំណោយពីព្រះសហគមន៍កាតូលិក។ លោកមានចាន់បន្តថា ភាពពិការនេះបានធ្វើឲ្យគាត់តូចចិត្តជាខ្លាំង ហើយលោកក៏កម្រចេញទៅណាដែរ ក្រៅពីនៅក្នុងផ្ទះដើម្បីស្ទោរជំឡូងឲ្យប្រពន្ធយកទៅលក់។ លោកមាន ចាន់បានឲ្យដឹងថា "សប្បាយក្រៃលែង និងរំភើបចិត្តតែម្តង ដែលបានមកលើកទី១នេះ។ បានអំណោយដែលអង្គការ (ព្រះសហគមន៍កាតូលិក) ចែកឲ្យនេះ (ខ្ញុំ)អរគុណច្រើន(សូមឲ្យ)បានវណ្ណៈសុខៈរហូតទៅ"។

អ្នកទទួលអំណោយម្នាក់ទៀត គឺអ្នកស្រីស៊ុន ចាន់ធីអាយុ៤៦ឆ្នាំ ជាជនពិការជើងពីកំណើតបានរៀបរាប់ថា ជីវិតជាជនពិការរបស់អ្នកស្រីត្រូវគេរើសអើងតាំងពីតូចមក ទាំងនៅក្នុងក្រុមគ្រួសារ និងមជ្ឈដ្ឋានជុំវិញ រហូតដល់មានគ្រួសារផ្ទាល់ខ្លួន។ អ្នកស្រីចាន់ធី និយាយថា "តាំងពីខ្ញុំដឹងក្តីមកថាខ្ញុំពិការភាពអីចឹង ខ្ញុំមានអារម្មណ៍តូចចិត្ត និងខ្មាស់គេ។ សម្រាប់ដល់ថ្ងៃនេះ ខ្ញុំដើរទៅរៀន រៀនរហូតដល់ខ្ញុំប្រឡងបាក់ឌុបជាប់ ខ្ញុំស្វែងរកការងារធ្វើដោយខ្លួនឯងទៀត អត់មានក្រុមគ្រួសារណាជួយទេ។ រហូតដល់ខ្ញុំរៀបការ រហូតដល់ខ្ញុំមានកូន២ទៀត"។ អ្នកស្រីបានឲ្យដឹងទៀតថា មិនត្រឹមតែក្នុងរង្វង់គ្រួសារមិនគាំទ្រជនពិការនោះទេ រីឯមជ្ឈដ្ឋានជុំវិញរបស់អ្នកស្រីក៏មានការរើងអើងផងដែរ។

អ្នកស្រី ចាន់ធី បានផ្តាំដល់ជនពិការទាំងអស់កុំឲ្យបាក់ទឹកចិត្ត ត្រូវមានការតស៊ូ កុំដេកដួលតាមភាពពិការរបស់ខ្លួន ត្រូវខិតខំរៀនសូត្រដើម្បីទទួលបានការងារធ្វើ។

ដោយមើលឃើញនូវការលំបាករបស់ជនពិការនិងគ្រួសាររបស់ពួកគាត់ លោកអភិបាលអូលីវីយេ បានសំណូមពរដល់ស្ថាបន និងព្រះវិហារនៃព្រះសហគមន៍កាតូលិកក្នុងភូមិភាគភ្នំពេញទាំងអស់ឲ្យហ៊ានទទួលជនពិការធ្ងន់ធ្ងរដើម្បីមើលថែរក្សា។ លោកអភិបាលអូលីវីយេ "តាមសំណូមពររបស់ខ្ញុំ គឺព្រះសហគមន៍របស់យើងត្រូវតែយកចិត្តទុកដាក់ជាពិសេសមនុស្សដែលសង្គមមើលមិនឃើញ មានក្រុមមួយ គឺមនុស្សពិការធ្ងន់ទាំងរូបកាយនិងប្រាជ្ញាជាទូទៅរៀនមិនបានទេ គេធ្វើការមិនបានទេហើយមួយចំនួនគេហូបបាយខ្លួនឯងមិនបានទេ គេថែរក្សាខ្លួនឯងក៏មិនបានដែរ"។ លោកអភិបាលសូមឲ្យព្រះសហគមន៍នីមួយៗហ៊ានទទួលក្រុមនេះតាមសមត្ថភាព ២ឬ៣នាក់ ដើម្បីជួយថែរក្សាគេ ឬយ៉ាងតិចជួយលើកទឹកចិត្ត និងជួយឪពុកម្តាយអំពីរបៀបថែរក្សា និងធ្វើចលនាសរសៃឲ្យកូនរបស់ពួកគាត់។

លោកអភិបាលបញ្ជាក់ទៀតថា "កិច្ចការនេះ គឺដើម្បីឲ្យគេយល់ថាជីវិតរបស់កូនក្មេងនេះមានតម្លៃណាស់។ យើងឃើញប៉ុន្មានដងនូវភាពញញឹមរបស់គេជាសញ្ញាសម្គាល់ពិតមែនគេមានអំណរសប្បាយ និងមានសេចក្តីសុខដូចមនុស្ស ផ្សេង"។

ក្នុងកម្មវិធីចែកអំណោយនិងសួរសុខទុក្ខបងប្អូនពិការនិងអ្នកជំងឺនេះ ព្រះវិហារសន្តសិលា និងសន្តប៉ូលបានចែកជូននូវអង្ករ និងគ្រឿងឧបភោគបរិភោគមួយចំនួនទៀត។

កម្មវិធីនេះដូចគ្នានេះ ត្រូវបានព្រះសហគមន៍កាតូលិកក្នុងភូមិភាគភ្នំពេញ ដែលមាន ៩ មណ្ឌលសកម្មភាពបានរៀបចំឡើងមានសកម្មភាពដូចជា សួរសុខទុក្ខអ្នកជំងឺ និងជនពិការតាមមណ្ឌលថែទាំសួរសុខទុក្ខតាមផ្ទះនិងផ្តល់សម្ភារមួយចំនួន និងរៀបចំពិធីជប់លៀងហូបអាហាររួមគ្នាជាដើម។ *ដោយកញ្ញា*





# ពិធីតែងតាំងជាឧបដ្ឋាកថ្មីនៅព្រះវិហារសន្តមីកាអែល

មានមនុស្សប្រមាណជាង ៧០០នាក់ ពោរពេញទៅដោយអំណរសប្បាយចូលរួមក្នុងពិធីតែងតាំងឧបដ្ឋាកថ្មី នៅព្រះវិហារសន្តមីកាអែល ក្រុងព្រះសីហនុ។ បេក្ខជនលោក ឆាល លេជី ផាន ជាជនជាតិ កេនយ៉ា ត្រូវបានត្រាស់ហៅយ៉ាងឱឡារិក ដោយលោកអភិបាល អូលីវីយេ ដ្មឺតអឺស្លែរ ដើម្បីតែងតាំងជាឧបដ្ឋាក់ នៃក្រុមសាសនទូត យ៉ារ៉ូម៉ាល់ ដែលមានប្រភពមកពីប្រទេសកូឡុំប៊ី។

ពិធីនេះបានប្រារព្ធទៅកាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៦ ដោយមានការចូលរួមជាកិត្តិយសរបស់លោកអភិបាលភូមិភាគបាត់ដំបង អេនរីគេ ហ្វីការេដូ រួមជាមួយបូជាចារ្យទាំងបីភូមិភាគបាត់ដំបង កំពង់ចាម និងភ្នំពេញ ជាពិសេសគឺវត្តមានរបស់លោកអគ្គអភិបាល មកពីប្រទេសសិង្ហបូរីផងដែរ។

ពិធីនេះបានចាប់ផ្តើមដោយក្បួនដង្ហែរបស់បូជាចារ្យ អភិបាលជាអធិបតី និងបេក្ខជនឧបដ្ឋាកដែលនាំមុខដោយក្រុមយុវតីក្នុងសំលៀកបំពាក់ប្រពៃណីអារវេ និងសំពត់ចងក្បិនយ៉ាងស្រស់សោភា។

តំណាងក្រុមសាសនទូត យ៉ារូម៉ាល់ លោក ហ្វេរណាន់ដូ បានផ្តល់សាក្ខីភាពថា លោក ឆាល ពិតជាមានសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើជាឧបដ្ឋាកពិតមែន និងបានស្នើសុំឲ្យលោកអភិបាលតែងតាំងលោកឆាលជាឧបដ្ឋាក។

ដោយមានសក្ខីភាពខាងលើ នៅមុខគ្រីស្តបរិស័ទជាច្រើន លោកអភិបាល អូលីវីយេ ហៅលោកឆាល មកបង្ហាញខ្លួនជាសាធារណៈ ដើម្បីទទួលពិធីតែងតាំងជាឧដ្ឋាក និងប្រកាសពាក្យសន្យារបស់លោកចំពោះមុខព្រះសហគមន៍។

នៅចំពោះមុខលោកអភិបាល និងគ្រីស្តបរស័ទទាំងអស់ បេក្ខជន ឆាល បានឆ្លើយតបដោយប្រកាសថា ៖ "បាទ! ខ្ញុំសុខចិត្ត" នឹងរស់នៅលីវអស់មួយជីវិតសម្រាប់ព្រះរាជ្យនៃស្ថានបរមសុខដោយគោរពបម្រើព្រះជាម្ចាស់ និងបងប្អូនឯទៀតៗក្នុងសេចក្តីស្រឡាញ់ និងស្តាប់បង្គាប់លោកអភិបាល ព្រមទាំងបំពេញមុខងារដោយចិត្តមេត្តាករុណា បញ្ជូនបន្តជំនឿរបស់ព្រះសហគមន៍ និងរស់នៅដោយយកគំរូតាមព្រះគ្រីស្ត។

បន្ទាប់ពីបេក្ខជនបានសន្យាស្របតាមលក្ខ័ណ្ឌទាំងឡាយរបស់ព្រះសហគមន៍កាតូលិក លោកឧបដ្ឋាកបានក្រាបចុះដល់ដី។ លោកអភិបាល អស់លោកបូជាចារ្យ និងគ្រីស្តបរិស័ទទាំងអស់លុតជង្គង់ ដោយទុកចិត្តលើព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ រួមជាមួយសន្តបុគ្គលទាំងឡាយ ដើម្បីទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គចាក់បង្ហូរព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធមកលើលោកឧបដ្ឋាកថ្មី ឆាល លេជីផាន។

កម្មវិធីបន្ត គឺពិធីបំពាក់អាវឧបដ្ឋាក និងលោកអភិបាលប្រគល់ព្រះគម្ពីរដើម្បីប្រកាសព្រះបន្ទូល និងជឿលើព្រះបន្ទូល ដោយរស់នៅស្របទៅតាមសេចក្តីដែលព្រះយេស៊ូបានប្រៀនប្រដៅ។

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ក្នុងធម្មទេសនាដែលចូលរួមក្នុងពិធីថា ៖ ឧបដ្ឋាក គឺមានន័យថា ជាអ្នកបម្រើ និងជាសញ្ញាសម្គាល់ព្រះយេស៊ូដែលជាអ្នកបម្រើ គឺបម្រើអ្នកក្រីក្រ និងមានសិទ្ធិធ្វើពិធីបុណ្យ អគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាអាពាហ៍ពិពាហ៍ដែរ នៅក្នុងនាមជាឧបដ្ឋាក។ លោកបន្តថា ៖ ជីវិតជាឧបដ្ឋាក គឺបម្រើនៅក្នុងអភិបូជា និងមប្រើនៅក្នុងជីវិតរបស់គេផ្ទាល់ ដោយបង្ហាញពីព្រះយេស៊ូ។ លោកអភិបាល បានបញ្ជាក់ថា ជីវិតរបស់ឧបដ្ឋាករំឭកយើងអំពីជីវិតដែលពោរពេញដោយសេចក្តីស្រឡាញ់លុះត្រាតែយើងយកចិត្តទុកដាក់បម្រើដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន។

ក្នុងធម្មទេសនាលោកអភិបាលបានរំឭកទៀតថា៖ ព្រះនាងម៉ារីគឺជាឧបដ្ឋាកមុនគេបង្អស់ ហេតុនេះលោកសូមឲ្យលោកឆាល មើល និងយកគំរូតាមការបម្រើរបស់ព្រះនាងម៉ារី លោកបន្តដោយសំណូមពរឲ្យលោកឆាល ចេញទៅសួរសុខទុក្ខបងប្អូននៅតាមផ្ទះនីមួយៗដូចព្រះនាងម៉ារីដែរ មិនតែប៉ុណ្ណោះសូមយកចិត្តទុកដាក់ក្នុងការអធិដ្ឋាន និងគោរពពិធីបុណ្យនានាតាមព្រះសហគមន៍កាតូលិកដូចព្រះនាងម៉ារី និងលោកយ៉ូសែប។ លើសពីនេះទៅទៀត គឺចូលទៅក្នុងវប្បធម៌នៅក្នុងប្រទេសម្ពុជា។ អ្វីដែលយើងធ្វើដំបូង គឺចូលទៅក្នុងចិត្តរបស់ប្រជាជនខ្មែរដើម្បីឲ្យយើងរួមគ្នាជាធ្លុងតែមួយនៅលើទឹកដីកម្ពុជា ដែលជាក្តីសង្ឃឹមរបស់សាសនទូតដូចព្រះនាងម៉ារីកចូលយ៉ាងជ្រៅនៅក្នុងទំនៀមទំលាប់ដែរ។

ក្រោយពីទទួលបានការតែងតាំងនេះ លោកឧបដ្ឋាកថ្មីត្រូវបានទទួលភារកិច្ចពីលោកអភិបាលអូលីវីយេ ដើម្បីបម្រើព្រះសហគមន៍មណ្ឌលសកម្មភាពតាកែវ ចាប់ពីខែកក្កដា ២០១៦នេះតទៅ។

លោកឧបដ្ឋាកថ្មីក្នុងវ័យ ៣២ឆ្នាំ ដែលប្រសូតចេញពីក្រុមគ្រួសារគ្រីស្តបរិស័ទជនជាតិភាគតិច កេនយ៉ា និងជាកូនប្រុសច្បងក្នុងចំណោមបងប្អូន ៦នាក់បាននិយាយថា "នេះជាអំណរសប្បាយមួយនៅក្នុងជីវិត ហើយការសម្រេចទទួលពិធីតែងតាំងជាឧបដ្ឋាកនៅលើទឹកដីកម្ពុជា គឺជាទំនៀមទំលាប់របស់ក្រុមសាសនទូតក្រៅប្រទេសយ៉ារ៉ូម៉ាល់"។ លោកបង្ហើបឲ្យដឹងទៀតថា ៖ បន្ទាប់ពីលោកទៅបម្រើព្រះសហគមន៍តាមការចាត់តាំងរបស់លោកអភិបាល លោកនឹងត្រលប់ទៅប្រទេសកំណើតដើម្បីទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅចុងឆ្នាំ ២០១៦នេះ ហើយនឹងវិលត្រលប់មកបម្រើព្រះសហគមន៍កម្ពុជាវិញនៅដើមឆ្នាំ ២០១៧។

លោកបូជាចារ្យប្រធានក្រុមសាសនទូតយ៉ារ៉ូម៉ាល់ ប្រចាំប្រទេសថៃ និងកម្ពុជា អាន់ ជ្រេ (Andrés Felipe Jaramillo Gutírrez) មានប្រសាសន៍ថា នេះជាមោទនភាពដែលមានបងប្រុសឆាល ជាឧបដ្ឋាកនៃក្រុមយ៉ារ៉ូម៉ាល់មុនគេបង្អស់ របស់អំបូរជនជាតិភាគតិចនៅកេនយ៉ា។ ហើយចំពោះឧបដ្ឋាកថ្មី អ្វីដែលសំខាន់គឺគាត់បានបង្ហាញអំពីវត្តមាន និងបេសកម្មរបស់យើងនៅប្រទេសកម្ពុជា។

លោកបូជាចារ្យម្ចាស់ផ្ទះ អ៊ុន សុន បានថ្លែងអំណរគុណដោយបង្ហាញនូវភាពសោមនស្ស ចំពោះក្រុមសាសន៍ទូតប្រកាសដំណឹងល្អក្រៅប្រទេសយ៉ារ៉ូម៉ាល់ និងព្រះសហគមន៍កាតូលិក ដែលបានផ្តល់ឱកាសជាប្រវត្តិសាស្ត្រដល់ព្រះសហគមន៍មណ្ឌលសកម្មភាពកំពង់សោមដើម្បីរៀបចំប្រារព្ធពិធីតែងតាំងជាឧបដ្ឋាកនេះ ហើយក៏ជាលើកដំបូងដែលមានពិធីបែបនេះនៅក្នុងព្រះវិហារសន្ត មីកាអែលដែលមានអាយុ៥០ឆ្នាំកន្លងមក។

ក្រុមសាសនទូត យ៉ារូម៉ាល់បានមកដល់ប្រទេសកម្ពុជានៅក្នុងទស្សវត្ស ១៩៩០។ នេះជាលើកទីបី ហើយដែលក្រុមសាសនទូតនេះ បានតែងតាំងឧបដ្ឋាករបស់ខ្លួននៅប្រទេសកម្ពុជា។ សព្វថ្ងៃសាសនទូតយ៉ារ៉ូម៉ាល់នៅប្រទេសកម្ពុជា មានសមាជិកចំនួនបីរូប កំពុងបម្រើនៅក្នុងភូមិភាគទាំងបី បាត់ដំបង កំពង់ចាម និងភ្នំពេញ។



*ដោយ ដាលីស*

# ព្រះសហគមន៍កាតូលិករំលឹកដល់មរណសាក្សីក្នុងជំនឿនៅសម័យសង្គ្រាម ១៩៧០-១៩៧៩



គ្រីស្តបរិស័ទប្រមាណជិតពីរពាន់នាក់ នៃព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា បានធ្វើដំណើរពីកន្លែងផ្សេងគ្នាតាមរថយន្ត មកកាន់ដីនៃក្ដីសង្ឃឹមនៅតាំងគោក ក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២០ ឧសភា ២០១៦ កន្លងទៅនេះ ដើម្បីចូលរួមប្រារព្ធពិធីរំលឹកដល់អ្នកដែលបានបូជាជីវិតរបស់ខ្លួនដោយរក្សាជំនឿយ៉ាងមាំមួនក្នុងស្ថានភាពដ៏លំបាកបំផុត នៅក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩។ ពិធីនេះប្រារព្ធទៅបានក្រោមអធិបតីភាពលោក អូលីវីយេ ជ្មឹតអីស្លឺរ៉េ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងលោកអែនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង។

ពិធីបុណ្យបានចាប់ផ្ដើមនៅវេលាម៉ោង៩ព្រឹក ដោយមានក្បួនដង្ហែចូលក្នុងពិធីបុណ្យដែលមានរបាំប្រពៃណីខ្មែរនាំមុខលោកបូជាចារ្យ និងលោកអភិបាលទៅកាន់ឈើឆ្កាងមរណសាក្សី ដែលនៅចំកណ្ដាលទីធ្លាប្រារព្ធពិធី។ លោកបូជាចារ្យគោរពឈើឆ្កាង ហើយលោកអភិបាលអុជធូបគោរពឈើឆ្កាង ដោយនឹកដល់ មរណសាក្សីទាំងឡាយ។ បន្ទាប់មកក្បួនដង្ហែបន្តទៅកាន់តុអសនៈ អមដោយចម្រៀងសរសើរតម្កើងព្រះជាម្ចាស់។ ពិធីបុណ្យបានបន្តតាមលំដាប់លំដោយតាមក្បួនពិធីរបស់ព្រះសហគមន៍កាតូលិក ដោយមានពិធីលើកតម្កើងព្រះបន្ទូលជាដើម។

នៅក្នុងធម្មទេសនាលោកអភិបាលអូលីវីយេ បានអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរបស់រមណសាក្សី ដែលជាគំរូសម្រាប់គ្រីស្តបរិស័ទក្នុងការថែរក្សាជំនឿ ដោយទុកចិត្តលើព្រះជាម្ចាស់គ្រប់កាលៈទេសៈ និងរស់នៅស្របទៅតាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។

លោកអភិបាលក៏បានលើកឡើងថា ព្រះសហគមន៍ទាំងបីភូមិភាគបានជួបជុំគ្នាថ្ងៃនេះ ពិតមែនបង្ហាញថាយើងជាក្រុមគ្រួសារតែមួយ ដូចព្រះបន្ទូលព្រះយេស៊ូថា៖ " ព្រះបិតា និងព្រះបុត្រាទៅជាអង្គតែមួយ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ"។

នៅមុខឈើឆ្កាងមរណសាក្សី និងព្រះបន្ទូលដែលជាសញ្ញាសម្គាល់អំពីជីវិតដែលគ្រីស្តបរិស័ទបានទទួល។ លោកអភិបាល អូលីវីយេ ក៏មានប្រសាសន៍ជំរុញឲ្យគ្រីស្តបរិស័ទ និងអ្នកគង្វាលព្រះសហគមន៍ឲ្យចេះថែរក្សាបងប្អូនឯទៀតៗដូចជា គ្រួសារតែមួយដូចបងប្អូនបង្កើត និងណែនាំអ្នកដែលបែកបាក់ឲ្យមករួមគ្នាតែមួយដូចព្រះបិតា។

លោកបានសង្កត់ធ្ងន់ថា ៖ " ខ្ញុំជឿថាសម្រាប់ព្រះសហគមន៍ទាំងមូល យើងបានទទួលអំណោយទានយ៉ាងច្រើន និងបានទទួលកម្លាំងថ្មីម្ដងទៀតដើម្បីបន្តទៅប្រកាសដំណឹងល្អ ពីឈើឆ្កាងនៃមរណសាក្សីនៅទីនេះនិង ដើម្បីឲ្យគ្រីស្ត បរិស័ទទាំងអស់ទាំងលោកបូជាចារ្យ និងលោកអភិបាលរួមជាមួយគ្នា ដើម្បីសាបព្រោះព្រះហឫទ័យប្រណីសណ្ដោសរបស់ព្រះជាម្ចាស់ នៅគ្រប់ទីកន្លែងក្នុងគ្រប់ព្រះសហគមន៍នៅកម្ពុជា និងនៅក្នុងសង្គមកម្ពុជាដែរ។ ខ្ញុំអរព្រះគុណព្រះជាម្ចាស់! យើងបន្តកសាងសេចក្ដីសង្ឃឹម និងសេចក្ដីសុខសាន្ត ដោយសារតែយើងមានព្រះគ្រីស្តគង់នៅជាមួយយើង។ អរគុណមរណសាក្សីទាំងឡាយ ដែលធ្វើដំណើរជាមួយយើងជានិច្ច"។

លើសពីនេះទៅទៀតនោះ តាមរយៈព្រះយេស៊ូជាសេចក្ដីពិត ដែលជាចិត្តស្រឡាញ់ បម្រើ អធិដ្ឋាន និងលើកលែងទោស លោកអភិបាលជំរុញគ្រីស្តបរិស័ទឲ្យអនុវត្តន៍សេចក្ដីពិតដូចព្រះយេស៊ូនៅក្នុងសង្គម និងដោយមានចិត្តស្មោះត្រង់មិនពុករលួយ ហើយក៏មិនមានល្បិច។

នៅក្នុងនោះលោកអភិបាលបានរំឭកដល់គ្រីស្តបរិស័ទទាំងអស់ឲ្យយកចិត្តទុកដាក់នឹងរបស់របរផ្សេងៗ មានគ្រែជាដើមដែលលោកអភិបាលសាឡាស់ និងសហការីបានប្រើសម្រាប់គេង និងថ្វាយអភិបូជាចុងក្រោយ នៅក្នុងសម័យខ្មែរក្រហមមុនអស់លោកចេញដំណើរស្វែងរកគ្រីស្តបរិស័ទក្នុងពេលនោះ។ លោកថា របស់របរទាំងនោះ ជារបស់សក្ការៈត្រូវគោរពឲ្យតម្លៃ និងថែរក្សា។

បន្ទាប់ពីធម្មទេសនារបស់លោកអភិបាលដែលបានលើកទឹកចិត្តគ្រីស្តបរិស័ទរួចមកពិធីបុណ្យបានបន្ត ដោយពិធីអរព្រះគុណព្រះជាម្ចាស់(អភិបូជា)។ មុនបញ្ចប់ពិធីក៏មានរាំរបាំប្រពៃណីអំពីមរណសាក្សីនៅជុំវិញឈើឆ្កាងផងដែរ។

ក្រោយអភិបូជា គ្រីស្តបរិស័ទបានអធិដ្ឋាន នៅក្នុងខ្ទមលោកអភិបាលឆ្នារ សាឡាស់ ដោយមានគ្រែដែលជាអាសនៈសក្ការៈលោកសាឡាស់នៅក្នុងការប្រារព្ធបុណ្យអភិបូជាចុងក្រោយ និងមុខរូបថតរបស់មរណសាក្សីមួយចំនួន ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគាត់ ព្រមទាំងសូមឲ្យមរណសាក្សីទាំងនោះជួយទូលអង្វរព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជា។

តាំងពីឆ្នាំ២០០០ សម្ដេចប៉ាប បានអនុញ្ញាតឲ្យព្រះសហគមន៍កាតូលិកនៅកម្ពុជាអាចប្រារព្ធពិធីចងចាំអ្នកដែលបានស្លាប់ព្រោះជំនឿ នៅក្នុងគ្រាលំបាកក្នុងប្រទេសរបស់ខ្លួន។ ព្រះសហគមន៍កាតូលិកក៏បានជ្រើសទឹកដីនៅភូមិតាំងគោក នៅជិតភូមិភាគទាំងបី និងជាទីតាំងដែលនៅជាប់ជាមួយជីវិតរបស់លោកយ៉ូសែប ឆ្នារ សាឡាស់ ជាអភិបាលព្រះសហគមន៍កាតូលិកលោកបូជាចារ្យ និងគ្រីស្តបរិស័ទជាច្រើន ដែលបានត្រូវសម្លាប់ និងស្លាប់ក្នុងសម័យខ្មែរក្រហម នៅតំបន់ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ព្រះសហគមន៍ក៏បានយកដីនិមិត្តរូប គ្រប់កន្លែងដែលគ្រីស្តបរិស័ទបានស្លាប់មកដាក់បញ្ចូលនៅទីនេះ មានសង់ឈើឆ្កាង និងផ្ទះលោកសាឡាស់ ក្នុងសម័យខ្មែរក្រហម។ ដោយឲ្យឈ្មោះទីកន្លែងនេះថា "ដីមរណសាក្សី ឬដីនៃក្ដីសង្ឃឹម" បើទោះបីព្រះសហគមន៍សកលមិនទាន់ទទួលស្គាល់ មរណសាក្សីនៅកម្ពុជាជាសកលក៏ដោយ។

ពីឆ្នាំ២០១៥ ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានបង្កើតតុលាការ ដើម្បីធ្វើការស៊ើបអង្កេត បញ្ចូលឈ្មោះបងប្អូនគ្រីស្តបរិស័ទដែលស្លាប់ព្រោះជំនឿទាំងនោះ ក្នុងបញ្ជីឈ្មោះមរណសាក្សីសកល។ ដំណើរការរបស់តុលាការនេះ កំពុងតែបន្តកិច្ចការរបស់ខ្លួន។ នៅក្នុងឆ្នាំមហាករុណាទិគុណសម្ដែងព្រះហឫទ័យប្រណីសន្ដោសព្រះសហគមន៍ភូមិភាគភ្នំពេញបានតាំងបូជនីដ្ឋានពីជីវិតមរណសាក្សី ដើម្បីឲ្យគ្រីស្តបរិស័ទកាន់តែចាប់អារម្មណ៍ខ្លាំងឡើងៗ និងស្គាល់ពីជីវិតបងប្អូនទាំងនោះកាន់តែច្បាស់ឡើងៗ ដោយជាប់ជាមួយជំនឿរបស់គេ។

*ដោយ ជា លីស*

# រកឃើញបំណែកយន្តហោះអេហ្ស៊ីបក្នុងសមុទ្រមេឌីទែរ៉ាណេ

អេហ្ស៊ីបបានរកឃើញបំណែកដូចជា កៅអី និងអីវ៉ាន់ពីយន្តហោះរបស់ក្រុមហ៊ុនអេស៊ីបអែរដែលបាត់ដាននៅលើសមុទ្រមេឌីទែរ៉ាណេ ខណៈពេលដែលក្រុមអ្នកស៊ើបអង្កេតព្យាយាមដោះស្រាយ មូលហេតុនៃការបាត់ដានដ៏អាថ៌កំបាំង។

ក្រុមមន្ត្រីបានអះអាងថា យន្តហោះនេះមុនធ្លាក់ គឺមានសញ្ញាដែលគេសង្ស័យថា វាវិលខ្វាល់មុនពេលបាត់ដាន ប៉ុន្តែមិនមានសញ្ញា សុំជំនួយពីអ្នកបើកបរឡើយ។

យោធាបាននិយាយថា ក្រុមរុករកបានប្រទះឃើញរបស់របរផ្ទាល់ខ្លួនរបស់អ្នកដំណើរ និងផ្នែកជាច្រើនរបស់យន្តហោះ Airbus A320 នៅប្រហែល ២៩០ គីឡូម៉ែត្រ ភាគខាងជើងទីក្រុង ឆ្នេរសមុទ្រ Alexandria របស់អេហ្ស៊ីប។

រដ្ឋមន្ត្រីអាកាសចរណ៍អេហ្ស៊ីបនិយាយថា "ការវាយប្រហារភេរវកម្ម" ទំនងជាមូលហេតុបង្កជាជាងកំហុសបច្ចេកទេស សម្រាប់ការបាត់ខ្លួនរបស់យន្តហោះដែលមកពីប៉ារីសទៅទីក្រុងគែរជាមួយមនុស្ស ៦៦ នាក់នៅលើនោះ។

សោកនាដកម្មនេះបានបង្កការព្រួយបារម្ភអំពីការបំផ្ទុះគ្រាប់ជាថ្មីលើយន្តហោះអ្នកដំណើររុស្ស៊ីពីសំណាក់ក្រុមរដ្ឋអ៊ីស្លាម (IS) កាលពីខែតុលាឆ្នាំមុនលើប្រទេសអេហ្ស៊ីបដែលបានសម្លាប់អ្នកដំណើរទាំង ២២៤ នាក់ជិះលើនោះ។

ក្នុងទីក្រុងគែរ អ្នកស៊ើបអង្កេតរបស់បារាំង និងរបស់ក្រុមហ៊ុន Airbus គ្រោងជួបគ្នាជាមួយសមភាគីអេហ្ស៊ីបដើម្បីត្រួសត្រាយការស៊ើបអង្កេត។

កងទ័ពជើងទឹកបារាំងបាននិយាយថា នាវាល្បាតបារាំងដែលដឹកឧបករណ៍មានសមត្ថភាពស្វែងរកប្រអប់ខ្មៅរបស់យន្តហោះគ្រោងមកដល់នៅថ្ងៃអាទិត្យ ឬថ្ងៃច័ន្ទក្នុងតំបន់ដែលយន្តហោះនេះធ្លាក់។

ជុំវិញករណីនេះ សម្តេចប៉ាប ហ្វ្រង់-ស៊ីស្កូ ក៏បានចេញសេចក្តីថ្លែងមរណទុក្ខមួយជូនចំពោះជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេផងដែរ ។

## សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ស្នើក្រុមកីឡាករបាល់ទាត់អ៊ីតាលី បង្ហាញភាពជាកីឡាករពិតប្រាកដ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីពេលថ្មីៗនេះ បានជំរុញឲ្យក្រុមកីឡាករបាល់ទាត់ អ៊ីតាលី ឲ្យរិះគិតអំពីស្មារតីពិតប្រាកដអំពីកីឡា ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា អ្នកដែលលេងបាល់ទាត់ទាំងអស់ត្រូវតែយល់ថា ការលែង គឺមិនមែនដើម្បីតែ ជើងឯកនោះទេ គឺត្រូវតែរិះគិតអំពី តម្លៃនៃសីលធម៌ និងភាពជាបងប្អូន ការគោរពគ្នាទៅវិញទៅមកយោគយល់ និងអត់ឱនឲ្យគ្នា។

ចំណាប់អារម្មណ៍របស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ គឺធ្វើឡើងនៅក្នុងពេលដែលក្លឹបពីរធំៗ នៅអ៊ីតាលី កំពុងតែប្រកួតប្រជែងគ្នាយកតំណែងជើងឯកប្រចាំឆ្នាំ រវាងក្លឹបជូវេនទុស និងក្លឹបអាសេមីលៀន។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា នៅក្នុងនាមជាអ្នកគាំទ្រកីឡាករបាល់ទាត់ណាម្នាក់ ដូចជា រូបសម្តេចផ្ទាល់ យល់ថា ឥរិយាបទ គឺជាចំណុចដ៏ទាក់ទាញបំផុតនៃចំណុចទទួលបានតម្លៃ និងការគាំទ្រពីក្រុមអ្នកនិយមកីឡា ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ការទាត់បញ្ចូលទីគឺជាជោគជ័យហើយ ប៉ុន្តែបើការទាត់នោះទៀតសោត ត្រូវទាត់ដោយសីលធម៌ ភាពស្មោះត្រង់ សាមគ្គីភាព មិត្តភាព គឺរឹតតែជា ចំណុចដែលគួរឲ្យចាប់អារម្មណ៍បំផុតរបស់កីឡាករ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានជំរុញឲ្យកីឡាករ រិះគិតអំពីតម្លៃ នៃមនសិកាភាពជាមនុស្ស ហើយនៅក្នុងពេលលេងគួរតែមានស្មារតី ជាបងប្អូនគោលរពនឹងឲ្យតម្លៃគ្នាទៅវិញទៅមក ។

## ចិនចោទប្រកាន់ មន្ត្រីជាន់ខ្ពស់មួយរូបទៀតពីបទ ពុករលួយ

អាជ្ញាធរចិនបានចោទប្រកាន់ជាផ្លូវការទៅលើលោក លីង ជីហ័រ (Ling Jihua) អតីតអ្នកជំនួយការរបស់អតីតប្រធានាធិបតី លោក ហ៊ូ ជីនតាវ ពីបទប្រព្រឹត្តអំពើពុករលួយ កាលពីថ្ងៃសុក្រ សប្តាហ៍មុននេះ។

លោក លីង ជីហ័រ ត្រូវបានគេដឹងថា គឺជាជនដ៏មានឥទ្ធិពលបំផុតមួយនៅក្នុងប្រទេសចិន កាលសម័យ ប្រធានាធិបតីមុន ហើយលោកគឺជាមន្ត្រីជាន់ខ្ពស់បំផុតដែលត្រូវគេចាប់ខ្លួន អំពីករណីប្រឆាំងនិងបទពុករលួយនេះ។

ក្រុមរដ្ឋអាជ្ញាបាននិយាយថា លោក ជីហ័រ បានទទួលប្រាក់សំណូក លួចការសម្ងាត់របស់រដ្ឋ និង រំលោភអំណាច។

លោក ជីហ័រ បានកាន់តំណែងជាន់ខ្ពស់ជាប្រធានការិយាល័យទូទៅនៃគណៈកម្មាធិការកណ្តាល នៅក្នុងរដ្ឋាភិបាលរបស់លោកហ៊ូ ជីនតាវ។

ក្រុមអាជ្ញាធរបានប្រកាសការស៊ើបអង្កេតលើលោក លីង ជីហ័រ កាលពីចុងឆ្នាំ២០១៤ ហើយលោកត្រូវបានបណ្តេញចេញពីបក្សកុម្មុយនីស្តហើយត្រូវបានចាប់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០១៥។

ការចាប់ខ្លួនរបស់លោក ជីហ័រ នេះគឺនៅក្នុងយុទ្ធនាការមួយរបស់ប្រធានាធិបតីចិនបច្ចុប្បន្ន លោក ស៊ី ជីនពីង ដែលបានចាត់ទុកថា ការធ្វើយុទ្ធនាការប្រឆាំងអំពើពុករលួយ ជាចំណុចស្នូលនៃរបៀបវារៈរបស់រដ្ឋាភិបាលរបស់លោក។ នៅក្នុងឆ្នាំ២០១៥ ចិនបានធ្វើយុទ្ធនាការដ៏ធំប្រឆាំងនឹងអំពើពុករលួយ ហើយបានដាក់ទណ្ឌកម្មមន្ត្រីជិត៣០០.០០០នាក់៕

## សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បញ្ជូនតំណាងជាន់ខ្ពស់ទៅចូលរួមកិច្ចប្រជុំកំពូលអំពីមនុស្សជាតិពិភពលោក

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា នៅថ្ងៃទី២៣-២៤ ឧសភា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បញ្ជូនគណប្រតិភូជាន់ខ្ពស់មួយក្រុមទៅចូលរួមកិច្ចប្រជុំកំពូលអំពីមនុស្សជាតិដែលបានរៀបចំជាលើកទីមួយ នៅទីក្រុងអ៊ីស្តង់បូល ប្រទេសទួរគី។

នេះគឺជាកិច្ចប្រជុំធំបំផុត ដែលលោកបាន គីមូល អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បានអះអាងថា បានរៀបចំឡើង ចាប់តាំងពី សង្គ្រាមលោកលើកទីពីរ បានបញ្ចប់ទៅនោះ ។

កិច្ចប្រជុំកំពូលនេះ គឺបានទទួលការចូលរួម ពីតំណាងរដ្ឋាភិបាល អង្គការមនុស្សធម៌ និងជនរងគ្រោះ ដែលភាគច្រើន គឺកំពុងទទួលផលប៉ះពាល់ពីវិបត្តិនៃមនុស្សជាតិ និងតំណាងក្រុមហ៊ុនឯកជនធំៗមួយចំនួន ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ គ្រាន់តែវិបត្តិនៅក្នុងប្រទេសស៊ីរីមួយ គឺមានអ្នកដែលរងគ្រោះ គឺប្រមាណជា ៤,៣លាននាក់ ទៅ ៤,៧លាននាក់។ ពួកគេភាគច្រើនដែលជាកុមារ និងយុវជនក្រោមអាយុ ១៨ឆ្នាំ គឺមានប្រហែលជា ពាក់កណ្តាល ដែលបានរងគ្រោះខ្វះការអប់រំ មិត្តភ័ក្រការកំសាន្ត និងសេចក្តីសង្ឃឹមសម្រាប់ជីវិតទៅអនាគត ។

មន្ត្រីជាន់ខ្ពស់ដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានចាត់បញ្ជូនទៅមហាព្រឹត្តិការណ៍នេះ គឺមានលោក កាឌីណាល់ ព្យែត្រូវ ប៉ារ៉ូលីន រដ្ឋមន្ត្រីនៃក្រសួងកាបរទេស លោកអគ្គអភិបាល បែណាត អូហ្ស្រា ឯកអគ្គរដ្ឋទូត បុរីវ៉ាទីកង់ ប្រចាំនៅអង្គការស៊ីល់វ៉ាណូ តូម៉ាស៊ី ជាតំណាង បុរីវ៉ាទីកង់ នៅអង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ ។

## សម្តេចប៉ាប៖ ព្រះវិញ្ញាណបរិសុទ្ធ គឺជាការធ្វើឲ្យសកម្មភាពរបស់ព្រះយេស៊ូនៅមានជីវិត

ថ្លែងទៅកាន់គ្រិស្តបរិស័ទនាថ្ងៃនៃពិធីបុណ្យ ព្រះវិញ្ញាណយាងមក សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ថ្លែងថា ព្រះវិញ្ញាដ៏វិសុទ្ធ អាចជាសារមួយនាំការបង្រៀន ការអប់រំ របស់ព្រះយេស៊ូឲ្យមានជីវិត ហើយ ជួយ យើង ជាគ្រីស្តបរិស័ទ ឲ្យយល់ ហើយរស់នៅក្នុងជីវិត ប្រកបដោយសេចក្តីមេត្តាករុណា។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសាន៍ថា ព្រះវិញ្ញាបរិសុទ្ធគឺផ្តល់ឲ្យយើងនូវតួនាទីមួយ ឬក៏ពន្លឺមួយ នៃការបង្រៀន និងភាពចងចាំ។ ព្រះវិញ្ញាណដ៏បរិសុទ្ធមិននាំយកនូវការបង្រៀនណាមួយដែលខុសនោះទេតែគឺធ្វើឲ្យព្រះយេស៊ូនៅមានព្រះជន្ម និងសកម្ម នៅក្នុងការអប់រំមនុស្ស។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ព្រះយេស៊ូបានភ្ជាប់ការបង្រៀនអំពីសេចក្តី នៃមេត្តាករុណា ដាក់នៅក្នុងក្រអៅបេះដូងរបស់ទ្រង់ ហើយជួយយើងទាំងអស់គ្នា បញ្ច្រាបវាហើយក៏ដូចជា ជួយឲ្យសេចក្តីមេត្តាករុណា ក្លាយជាផ្នែកមួយ នៃជីវិតរបស់យើង ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា នេះគឺជាសារមួយដែលព្រះយេស៊ូប្រទានឲ្យគ្រីស្តបរិស័ទទទួលពរ ឬក៏ពាក្យសច្ចាពីព្រះជាម្ចាស់ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ សូមឲ្យបើកចិត្តគំនិត និងបេះដូងដើម្បីទទួលព្រះវិញ្ញាណដ៏បិរសុទ្ធ ដូចព្រះយេស៊ូទ្រង់បានសន្យា ដើម្បីបញ្ជូននូវសារទាំងនេះមកដល់យើងទាំងអស់គ្នា។



*លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូង៍*

### ថ្ងៃអាទិត្យទី ១០ ក្នុងរដូវធម្មតាឆ្នាំ គ (កាឡ ១,១១-១៩)
### ថ្ងៃទី ៥ ខែមិថុនា ២០១៦

មានគ្រីស្តបរិស័ទនៅស្រុកកាឡាទីខ្លះបានចោទលោកប៉ូលថា លោកបានប្រកាសដំណឹងល្អក្លែងក្លាយ។ ហេតុនេះ ក្នុងអត្ថបទនេះ លោកបញ្ជាក់ថា លោកបានទទួលដំណឹងល្អ និងមុខងារប្រកាសដំណឹងល្អពីព្រះជាម្ចាស់ផ្ទាល់ ព្រះអង្គបានត្រាស់ហៅនិងចាត់លោកដូចព្យាការីនៅជំនាន់មុន។ ក៏ប៉ុន្តែ លោកទៅជួបមេអ្នកដឹកនាំដ៏សំខាន់ៗរបស់ព្រះសហគមន៍ គឺលោកបានជួបបងសិលា និងបងយ៉ាកូប ដើម្បីរួមក្នុងជំនឿរបស់ព្រះសហគមន៍។

គ្រីស្តទូតប៉ូលមិនលាក់លៀមថា កាលពីមុន លោកកាន់សាសនាយូដាបែបជ្រុលនិយមតែព្រះជាម្ចាស់បានអាណិតអាសូរត្រាស់ហៅលោក។ ក្រោយមក លោកស្រឡាញ់ព្រះយេស៊ូយ៉ាងខ្លាំង ដូចលោកស្រឡាញ់ព្រះជាម្ចាស់កាលពីមុនដែរ។ មុនពេលយើងផ្ញើជីវិតលើព្រះគ្រីស្ត តើយើងស្វែងរកការសង្គ្រោះ គឺរកបរិនិព្វានបែបណា? មានតែអ្នកដែលកាន់តាមពុទ្ធសាសនាយ៉ាងខ្លាំង មានបទពិសោធន៍អំពីការសង្គ្រោះរបស់ព្រះគ្រីស្តបាន។ ព្រះគ្រីស្តធ្វើឲ្យព្រះឱវាទរបស់ព្រះពុទ្ធជាបរមគ្រូ កើតជារូបរាងក្នុងចិត្តនិងការរស់នៅប្រចាំថ្ងៃរបស់យើង។

### ថ្ងៃអាទិត្យទី១១ ក្នុងរដូវធម្មតាឆ្នាំ គ (កាឡ ២:១៦.១៩-២១)
### ថ្ងៃទី ១២ ខែមិថុនា ២០១៦

ពុទ្ធបរិស័ទក៏ដូចសាសនិកជនយូដាពីដើម គឺគេចង់បានសុចរិតដោយសន្សំកុសលផលបុណ្យ ដោយប្រតិបត្តិតាមធម្មវិន័យយ៉ាងល្អឥតខ្ចោះ។ នេះពិតជាការល្អប្រសើរ។ តែយើងជាគ្រីស្តបរិស័ទមិនពឹងផ្អែកលើកុសលផលបុណ្យទេ ផ្ទុយទៅវិញ យើងផ្ញើជីវិតលើព្រះយេស៊ូដែលបានស្រឡាញ់ព្រះបិតា និងផ្ញើជីវិតលើព្រះអង្គ រហូតដល់បូជា ព្រះជន្ម។ យើងមិនគ្រាន់តែជឿព្រះយេស៊ូ ឬជឿទ្រឹស្តី ឬធ្វើពិធីប៉ុណ្ណោះទេ តែយើងផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូ ដែលបានផ្ញើជីវិតលើព្រះបិតា និងស្រឡាញ់ព្រះអង្គក្នុងនាមយើងទាំងអស់គ្នា។ យើងក៏សុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ត ក្នុងគ្រប់កិច្ចការប្រចាំថ្ងៃ។ គ្រីស្តទូតប៉ូលធ្លាប់សរសេរថា យើងរួមក្នុងអង្គព្រះគ្រីស្ត គឺយើងធ្វើជារូបកាយតែមួយនឹងព្រះអង្គ។ ដោយជនជាតិយូដាកាន់តាមធម្មវិន័យយ៉ាងតឹងរឹង គេធ្វើគុតព្រះយេស៊ូយ៉ាងណា ពុទ្ធបរិស័ទក៏ធ្លាប់ស្តីបន្ទោសឲ្យយើងដែលបោះបង់សាសនាជាតិយ៉ាងនោះដែរ។ នៅពេលនោះ យើងពិតជាជាប់ឆ្កាង ជាមួយព្រះយេស៊ូមែន។ យើងជាគ្រីស្តបរិស័ទ មិនបំបាត់ធម្មវិន័យរបស់ព្រះពុទ្ធទេតែកាន់ធម្មវិន័យនេះដោយមាន ចិត្តគំនិតថ្មី ពោលគឺដោយចិត្តស្រឡាញ់។

### ថ្ងៃអាទិត្យទី១២ ក្នុងរដូវធម្មតាឆ្នាំ គ (កាឡ ៣, ២៦-២៩)
### ថ្ងៃទី ១៩ ខែមិថុនា ២០១៦

យើងជាគ្រីស្តបរិស័ទរួមជាមួយព្រះគ្រីស្ត ហាក់ដូចជា បំពាក់ព្រះអង្គដូចអាវមួយ។ អ្នកណាឃើញយើង ក៏ឃើញព្រះយេស៊ូដែរ។ ដូចលោកពីបុរាណធ្លាប់សរសេរថា គ្រីស្តបរិស័ទគឺជាព្រះគ្រីស្តមួយអង្គទៀត។ ព្យាការីយេស៊ូក្នុងឋានៈជាមនុស្សបានផ្ញើជីវិតលើព្រះបិតាក្នុងនាមមនុស្សទាំងអស់ ជាពិសេសនៅពេលគេឆ្កាងលោក សម្លាប់ចោល។ លោកបែររកព្រះបិតាក្នុងគ្រប់កាលៈទេសៈប្រចាំជីវិត។ ហេតុនេះ ប្រសិនបើយើងរួមស្លាប់រួមរស់ ជាមួយព្រះគ្រីស្តក្នុងគ្រប់កិច្ចការប្រចាំជីវិត យើងក៏ពិតជាបុត្រធីតារបស់ព្រះបិតាដោយរួមជាមួយព្រះគ្រីស្តដែរ។ អត្តសញ្ញាជ្រមុជទឹកបានការ លុះត្រាតែយើងផ្ញើជីវិតលើព្រះគ្រីស្ត ហើយសុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះអង្គ។ យើងក៏រាប់គ្រីស្តបរិស័ទឯទៀតៗ ទោះគេមានជាតិសាសន៍អ្វី ឬឋានៈវណ្ណៈក្នុងសង្គមអ្វី ឬការងារអ្វីក្តី ក៏យើងចាត់ ទុកគេជាព្រះគ្រីស្តដែរ។ យើងជាគ្រីស្តបរិស័ទមានទំនាក់ទំនងយ៉ាងស្និទ្ធស្នាលបំផុតជាមួយរៀមច្បងយេស៊ូ ដែលនាំយើងឲ្យស្និទ្ធស្នាលជាមួយព្រះបិតាដែរ ដូចយើងធ្លាប់សូត្រ "គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត" យើងមានផ្លូវទៅកាន់ព្រះបិតាដោយចិត្តសង្ឃឹម។

### ថ្ងៃអាទិត្យទី១៣ ក្នុងរដូវធម្មតាឆ្នាំ គ (កាឡ ៥,១.១៣-១៨ )
### ថ្ងៃទី ២៦ ខែមិថុនា ២០១៦

បងប្អូនខ្មែរតែងតែខ្លាចបាប គឺខុសទំនៀមទម្លាប់បន្តិចបន្តួចក៏បាប ចាស់ទុំសំពះក្មេងៗក៏បាប។ល។ ក្នុងអត្ថបទនេះ គ្រីស្តទូតប៉ូលរំឭកយើងជាគ្រីស្តបរិស័ទថា ព្រះគ្រីស្តបានរំដោះយើងពីនឹមនៃធម្មវិន័យរបស់លោកម៉ូសេ ដែលមានវិន័យរាប់រយដើម្បីបញ្ជាគេក្នុងគ្រប់កិច្ចកាប្រចាំថ្ងៃរបស់គេ។ យើងត្រូវកាន់វិន័យតែមួយ ដែលជាគោលដៅតែមួយក្នុងការរស់នៅរបស់យើង គឺត្រូវស្រឡាញ់អ្នកដទៃ និង ស្រឡាញ់ព្រះបិតាដោយចិត្តស្មោះ។ យើងជាគ្រីស្តបរិស័ទមិនគិតពីបុណ្យបាបទៀតឡើយ។ នេះជាសេរីភាពដែលព្រះគ្រីស្តប្រទានឲ្យយើង។ ដូចព្រះយេស៊ូមានព្រះបន្ទូលថា "វិន័យកើតមកសម្រាប់បម្រើមនុស្ស គឺមិនមែនឲ្យមនុស្សកើតមកសម្រាប់បម្រើវិន័យនោះទេ"។ តែសេរីភាពដ៏ពិតប្រាកដមកគឺពីសេចក្តីស្រឡាញ់។ យើងមិនប្រព្រឹត្តអំពើអាក្រក់ដោយខ្លាចបាបទេ តែដោយយើងមានបំណងស្រឡាញ់ព្រះបិតា និងស្រឡាញ់បងប្អូន។ តែយើងត្រូវប្រយ័ត្ន ព្រោះយើងមានតណ្ហាជាប់នឹងខ្លួនដែលចេះទាក់ទាញយើងឲ្យរកតែផលប្រយោជន៍ផ្ទាល់ខ្លួនភ្លាមៗ ប៉ុណ្ណោះ ហេតុនេះត្រូវតែអង្វរព្រះវិញ្ញាណឲ្យណែនាំយើងគ្រប់ពេលវេលា។

---

## កំណាព្យ ជីវិតចាស់ជរាគ្មានទីពឹង



*និពន្ធដោយអ្នកស្រី ខុង ណារី, មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និង សុខភាពនៃគម្រោងអភិវឌ្ឍន៍ជនបទ អង្គស្លួល / JSC*

(បទពាក្យ ៧)

១ - មាតាបិតាទាំងពីរអង្គ        លោកខំផ្ចិតផ្ចង់ថែរក្សា
បីបាច់ថ្នាក់ថ្នមពេញហត្ថា        គ្រប់បុត្រធីតាគ្មានឲ្យហ្មង ។
២ - ចិញ្ចឹមរក្សាតូចដល់ធំ        ពេញវ័យក្រមុំកម្លោះផង
ឲ្យរៀនចេះដឹងពុំមានឆ្គង        រៀបចំគូគ្រងបែកគ្រួសារ ។
៣- បានទាំងកូនគាប់ភ្ជាប់និស្ស័យ        មានកូនប្រុសស្រីក្តីប្រាថ្នា
សប្បាយរីករាយក្នុងចិន្តា        ជីវភាពគ្រួសារក៏សមរម្យ ។
៤- ភ្លេចម្តាយឪពុកទុកដោយឡែក        ព្រោះគាត់បានបែកចែកទ្រនំ
ចូលឆ្នាំទៅម្តងរដូវភ្ជុំ        ទៀនធូបចេកនំជូនពុកម៉ែ ។
៥- រដូវបុណ្យទានទើបជួបមុខ        កូនដែលម៉ែពុកថ្នាក់ថ្នមថៃ
តាំងពីប្រសូត្រចាកផ្ទៃម៉ែ        ដុំពេជ្រមាសស្នេហ៍ស្មើជីវិត។
៦- អាយុវ័យកាលចាស់ជរា        យាយតារងាឃើញភាពពិត
មួយឆ្នាំមានម្តងកូននឹកគិត        តើក្នុងជីវិតស្ថិតយ៉ាងណា ។
៧- ខ្លួនមានជំងឺឈឺប្រចាំ        ក្រពះស្រែកផ្តាំឃ្លានអាហារ
ទន្ទឹងផ្លូវកូនមកថ្ងៃណា        សម្លឹងភ្នែកផ្សាញ័រទាំងកាយ។
៨- ច្រើនថ្ងៃច្រើនខែកន្លងហួស        ឃ្លានស្ទើរដាច់ពោះព្រោះអត់បាយ
ជីវិតរស់នៅលែងសោកស្តាយ        ដើម្បីដោះស្រាយដល់ក្រពះ។
៩- ដាច់ចិត្តលើកដៃសុំទានគេ        ទូលទុក្ខរីតទ្វេព្រះជាម្ចាស់
ឈឺជារងាទ្រាំខ្លាំងណាស់        ប្រឹងប្រែងយកឈ្នះរស់មួយថ្ងៃ។
១០- សូមអស់កូនចៅគ្រប់រូបា        ដឹងគុណមាតាបិតាថ្លៃ
គុណលោកទាំងពីរធំធូន់ក្រៃ        មិនអាចរកអ្វីប្រៀបស្មើបាន។
១១- ត្រូវតែគិតគូរដល់គាត់ចាស់        នេះគឺជាព្រះកន្លោងស្ថាន
គ្រប់គ្រងរក្សាកូនគ្រប់ប្រាណ        ផ្តល់ក្តីសុខសាន្តគ្រប់ៗគ្នា ។

# រូបថតសកម្មភាពព្រះសហគមន៍កាតូលិក


















Radio Veritas Asia

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

# វិទ្យុវ៉ារីតាស់អាស៊ីខេមរភាសា

## សំលេងពីព្រះសហគមន៍កាតូលិកកម្ពុជា

| | | |
|---|---|---|
| **ភ្នំពេញ** | : FM 104 Mhz | **ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ** |
| **បាត់ដំបង** | : FM 91.0 Mhz | **ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ** |
| **សៀមរាប** | : FM 98.75 Mhz | **ម៉ោង ៥:០០- ៦:០០យប់ រាល់ថ្ងៃ** |
| **កំពង់ធំ** | : FM 103.5 Mhz | **ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ** |
| **កំពង់ចាម** | : FM 100.5 Mhz | **ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ** |
| **ព្រះសីហនុ** | : FM 100.5 Mhz | **ម៉ោង ៦:០០- ៧:០០ រាល់ថ្ងៃ** |
| **កំពត** | : FM 93.25 Mhz | **ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ** |

### ✣ ផ្សាយតាមរលកធាតុអាកាសខ្លី (SW)

ជាភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃពីម៉ោង ៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

### ✣ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវ៉ារីតាស់អាស៊ីភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬ ប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។




ឬ តាមរយៈវេបសាយ៖ http://khmer.rveritas-asia.org